ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# ផែនការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល ឆ្នាំ២០២៦-២០៣០

ខែមីនា ២០២៦
នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល

# អារម្ភកថា

**«ការលើកកម្ពស់សុខភាព និងសុខុមាលភាពពលរដ្ឋ»** ជាអាទិភាពគន្លឹះមួយនៃការអភិវឌ្ឍមូលធនមនុស្ស នៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និង **«ការពង្រីកសេវាថែទាំសុខភាពឆ្ពោះទៅកាន់ការគ្របដណ្តប់សុខភាពជាសកល»** ជាអាទិភាពទី១នៃកម្មវិធីគោលនយោបាយអាទិភាពចំនួន ៦ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ និងឈ្លាសវៃប្រកបដោយចក្ខុវិស័យច្បាស់លាស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រួមជាមួយនឹងការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាល ដែលផ្តោតលើការលើកកម្ពស់គុណភាពសេវាសុខាភិបាល និងការពង្រឹងសមត្ថភាពផ្តល់សេវាសុខភាពបឋមនៅមូលដ្ឋាន។ ការណ៍នេះត្រូវបានចាត់ទុកថាជាកាលានុវត្តភាពសម្រាប់វិស័យសុខាភិបាល ដែលត្រូវបន្តពង្រឹងសមត្ថភាពស្ថាប័នក្នុងការបម្រើសេវាថែទាំសុខភាពជូនប្រជាពលរដ្ឋ ដើម្បីចូលរួមចំណែកឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ រួមទាំងសុខភាព និងសុខុមាលភាពប្រសើរឡើងមួយកម្រិតថែមទៀត ដែលជាបំណងប្រាថ្នាធម្មានរូបរបស់ប្រជាពលរដ្ឋកម្ពុជា។

ក្រសួងសុខាភិបាលបានដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ២០២៥-២០៣៤ ដើម្បីពង្រឹងសមិទ្ធកម្មប្រព័ន្ធសុខាភិបាលឱ្យរឹងមាំ មានភាពធន់ ដោយត្រូវផ្តោតការយកចិត្តទុកដាក់ជាចម្បងលើការផ្តល់សេវាអប់រំលើកកម្ពស់សុខភាព សេវាបង្ការបឋម សេវាបង្ការដំណាក់កាលទីពីរ និងសេវាគ្រប់គ្រងស្ថានភាពឈឺធ្ងន់ធ្ងរ ប្រកបដោយប្រសិទ្ធភាព ទន្ទឹមគ្នានឹងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន សុខាភិបាលក្នុងប្រព័ន្ធសុខាភិបាល ដែលជាចំណែកដ៏ធំមួយមិនអាចខ្វះបាន ដើម្បីលើកកម្ពស់ការពង្រាយ មូលដ្ឋានសុខាភិបាលប្រកបដោយសមធម៌ ត្រៀមសេវារួចជាស្រេចសម្រាប់ការប្រើប្រាស់ និងលើកកម្ពស់គុណភាព។ ក្នុងឆ្នាំ២០២៥ រាជរដ្ឋាភិបាល បានផ្តល់ថវិកាក្នុងការកែលម្អហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល រួមមាន ការសាងសង់អគារមណ្ឌលសុខភាព ជួសជុលកែលម្អអគារសង្គ្រោះបន្ទាន់ និងវះកាត់ក្នុងមន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២ និងជួសជុលកែលម្អអគារមន្ទីរពិសោធន៍មួយចំនួនទៀត។

សមិទ្ធផល និងវឌ្ឍនភាពជាច្រើននៅក្នុងវិស័យសុខាភិបាល ត្រូវបានទទួលស្គាល់ជាបន្តបន្ទាប់ រួមមាន **ការថែទាំសុខភាពបឋមនៅតាមមូលដ្ឋានសុខាភិបាល** ជាពិសេស សុខភាព មាតា ទារក និងកុមារ ការធ្វើសមាហរណកម្មការផ្តល់សេវាបង្ការ និងព្យាបាលជំងឺមិនឆ្លង និងការគ្រប់គ្រងជំងឺឆ្លងចម្បងៗ **ការកែលម្អគុណភាពសេវា និងសុវត្ថិភាពអ្នកជំងឺ** ដែលជាអន្តរាគមន៍បង្កើនទំនុកចិត្តរបស់ប្រជាពលរដ្ឋមកលើប្រព័ន្ធសុខាភិបាល **វឌ្ឍនភាពឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកល**ក្នុងក្របខ័ណ្ឌនៃការពង្រឹងប្រព័ន្ធគាំពារសុខភាព និង**ការធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាល** ដែលឆ្លើយតបនឹងតម្រូវការថែទាំបង្ការ ការធ្វើរោគវិនិច្ឆ័យ ការថែទាំព្យាបាលឱ្យកាន់តែមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ ស្របតាមនិន្នាការវិវត្តនៃបន្ទុកជំងឺ និងភាពជឿនលឿននៃបច្ចេកវិទ្យាវេជ្ជសាស្ត្រ។

ផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល ជាឧបករណ៍គ្រប់គ្រងយុទ្ធសាស្ត្រ និងតម្រង់ទិសក្នុងការអភិវឌ្ឍមូលដ្ឋានសុខាភិបាលប្រកបដោយសមធម៌ ចីរភាព និងជំរុញភាពជឿនលឿននៃសមិទ្ធកម្មប្រព័ន្ធសុខាភិបាល នៅក្នុងបណ្ដាឆ្នាំខាងមុខ សំដៅបន្តលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាពលរដ្ឋ ឱ្យប្រសើរឡើងថែមទៀត។ ផែនការអភិវឌ្ឍន៍មូលដ្ឋានសុខាភិបាល ក៏បានដាក់ចេញនូវការព្យាករណ៍តម្រូវការមូលដ្ឋានសុខាភិបាលច្បាស់លាស់ ទាំងបរិមាណនិងកម្រិតសមត្ថភាពផ្ដល់សេវា នៅក្នុងបរិបទវិវត្តនៃវិមជ្ឈការនិងសហវិមជ្ឈការ និងបង្កើនការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយភាពបត់បែនក្នុងការសម្រួចសមត្ថភាពធនធានមនុស្សសុខាភិបាល និងលើកកម្ពស់ការប្រើប្រាស់ធនធានដែលមាននាពេលបច្ចុប្បន្ន និងក្នុងពេលអនាគត ប្រកបដោយប្រសិទ្ធភាព និងស័ក្ដិសិទ្ធភាព ដើម្បីតម្រង់ទិសដៅការផ្ដល់សេវាថែទាំសុខភាពឱ្យស័ក្ដិសមនឹងតម្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋាន។

តាងនាមឱ្យក្រសួងសុខាភិបាល ខ្ញុំសូមគាំទ្រ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ដែលបានផ្ដួចផ្ដើមគំនិតបង្កើតឱ្យមានប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ដើម្បីជំរុញនិងលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃដំណើរការរបស់អង្គភាព។ ជាមួយគ្នានេះផងដែរ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រុមការងារដឹកនាំ និងគ្រប់គ្រងគម្រោងលើកទឹកចិត្ត ដែលបានបង្កើតផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាលនេះឡើងដោយជោគជ័យ។

ក្រសួងសុខាភិបាលសង្ឃឹមយ៉ាងមុតមាំថា អង្គភាពសុខាភិបាលគ្រប់លំដាប់ថ្នាក់ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងស្ថាប័ន និងតួអង្គពាក់ព័ន្ធទាំងអស់ រួមទាំងដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល ចូលរួមយ៉ាងសកម្មក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល ដើម្បីឆ្ពោះទៅសម្រេចវឌ្ឍនភាព និងសមិទ្ធផលថ្មីៗបន្ថែមទៀត នៅក្នុងវិស័យសុខាភិបាលដែលនាំមកនូវអត្ថប្រយោជន៍សុខភាព និងសុខុមាលភាពកាន់តែប្រសើរឡើង ជូនប្រជាពលរដ្ឋកម្ពុជា នាពេលបច្ចុប្បន្ន និងជំនាន់ក្រោយ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៦

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

សាស្ត្រាចារ្យ **ឈាង រ៉ា**

# ខ្លឹមសារសង្ខេប

## ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន

១ ក្នុងឆ្នាំ២០២៤ កម្ពុជាមាន រាជធានីមួយ និងខេត្តចំនួន ២៤ ចែកចេញជា ៣២ ក្រុង ១៤ ខណ្ឌ ១៦៣ ស្រុក ២៦៩ សង្កាត់ ១ ៣៨៣ ឃុំ និង ១៤ ៥៧៧ ភូមិ។ រចនាសម្ព័ន្ធរដ្ឋបាលទាំងអស់ត្រូវបានគ្រប់គ្រងតាមច្បាប់អង្គការ។

២ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តត្រូវបានអភិវឌ្ឍន៍នៅតាមបណ្តារាជធានី ខេត្ត ផ្អែកតាមផែនការគ្របដណ្តប់សុខាភិបាល និងតាមការគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងការសាងសង់អគារនៃមូលដ្ឋានសុខាភិបាល ពីដៃគូសុខាភិបាល និងសប្បុរសជន។

៣ មូលដ្ឋានសុខាភិបាលបានកើនឡើង ១៤,0% គឺពី ១ ៣៧១ កន្លែង នៅឆ្នាំ២០១៦ ដល់ ១ ៥៦៣ កន្លែង នៅឆ្នាំ២០២៥ ស្របនឹងកំណើនប្រជាជន ១២,៥% គឺពី ១៥ ៦២៦ ៤៤៤នាក់ នៅឆ្នាំ២០១៦ ទៅ ១៧ ៥៧៧ ៧៥៩នាក់ នៅឆ្នាំ២០២៥ ដោយមណ្ឌលសុខភាព ១ បម្រើសេវាសុខភាពជូនប្រជាជនចំនួន ១៣ ៤២៤ នាក់ នៅឆ្នាំ២០១៦ និង ១៣ ៤០៧ នាក់ នៅឆ្នាំ២០២៥។

៤ ក្នុង៣ឆ្នាំចុងក្រោយ (២០២៣-២០២៥) មូលដ្ឋានសុខាភិបាលសាធារណៈត្រូវបានបង្កើតថ្មី និងដំឡើងកម្រិតជាមធ្យមក្នុងមួយឆ្នាំមានចំនួន ១៧ កន្លែង ដែលមណ្ឌលសុខភាពមានរហូតដល់ ៥២% និងប៉ុស្តិ៍សុខភាពបង្កើតថ្មី ៣៧%។ ត្រឹមឆ្នាំ២០២៥ មណ្ឌលសុខភាពមានចំនួន ១ ៣១១កន្លែង ប៉ុស្តិ៍សុខភាពចំនួន ១១៥ កន្លែង (មិនរាប់បញ្ចូលប៉ុស្តិ៍សុខភាពពន្ធនាគារដែលគ្រប់គ្រងដោយក្រសួងមហាផ្ទៃ) មន្ទីរពេទ្យជាតិចំនួន ១២ កន្លែង មន្ទីរពេទ្យរាជធានី ខេត្តចំនួន ២៥ កន្លែង និងមន្ទីរពេទ្យបង្អែកស្រុកចំនួន ៩៩ កន្លែង។

## សន្និដ្ឋានកម្ម

៥ **ពីរយៈពេលខ្លីទៅរយៈពេលមធ្យម(២០២៤-២០៣០)** លក្ខណៈវិនិច្ឆ័យទាំងពីរ «**ចំនួនប្រជាជន និងស្ថានភាពភូមិសាស្ត្រចូលទៅរកសេវា**» នៅតែមានភាពសមស្រប បើយោងតាមនិន្នាការកំណើនប្រជាជនធនធាននៅមានកម្រិត មណ្ឌលសុខភាពនិងមន្ទីរពេទ្យស្រុកជាច្រើនមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាពេញលេញ ស្របតាមសំណុំសកម្មភាពអប្បបរមា MPA និងសំណុំសកម្មភាពបង្គ្រប់ CPA ដែលបានកំណត់។

៦ ផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល រៀបចំឡើងផ្អែកតាមអភិក្រមប្រព័ន្ធសុខា-ភិបាលស្រុកប្រតិបត្តិ ស្របតាមការធ្វើបរិវត្តកម្មរចនាសម្ព័ន្ធ ដោយប្រើលក្ខណៈវិនិច្ឆ័យ **«ចំនួនប្រជាជន និងស្ថានភាពភូមិសាស្ត្រចូលទៅរកសេវា»** និងកម្រិតធនធានដែលមាន។

៧ ផែនការអភិវឌ្ឍន៍ក៏បានឆ្លើយតបនឹង៖ ទីមួយ. តម្រូវការចាំបាច់សម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្នុងការអភិវឌ្ឍមូលដ្ឋានសុខាភិបាលប្រកបដោយប្រសិទ្ធភាពចំណាយ ការសម្រេចអាទិភាព និងការឆ្លើយតបនឹងតម្រូវការសុខភាពសារវន្តរបស់ប្រជាពលរដ្ឋតាមភូមិសាស្ត្ររស់នៅ ទីពីរ. តម្រៀបបណ្តើរៗតំបន់ទទួលខុសត្រូវរបស់ស្រុកប្រតិបត្តិ ជាមួយព្រំប្រទល់ស្រុករដ្ឋបាល និងតំបន់ទទួលខុសត្រូវរបស់មណ្ឌលសុខភាពជាមួយព្រំប្រទល់ឃុំ ឬសង្កាត់ ទីបី. **ការបង្កើតមណ្ឌលសុខភាពថ្មី និងមន្ទីរពេទ្យបង្អែកថ្មី** ត្រូវពិចារណាពីប្រសិទ្ធភាពប្រព័ន្ធសុខាភិបាល និងផលចំណេញសេដ្ឋកិច្ចដែលនឹងទទួលបានមកវិញ ពីការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងលើធនធានមនុស្ស ព្រមទាំងសក្តានុពលនៃសេវាឯកជន និងទីបួន. អភិវឌ្ឍជាបណ្តើរៗ មណ្ឌលសុខភាពមានគ្រែជាអតីតពេទ្យស្រុកដែលមានលទ្ធភាព សក្តានុពលខ្ពស់ និងគ្របដណ្តប់ប្រជាជនសមស្រប ឱ្យទៅជាមន្ទីរពេទ្យបង្អែកកម្រិត១។

## គោលដៅផែនការអភិវឌ្ឍន៍

៨ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល ធានាឱ្យមានសង្គតិភាព ចីរភាព និងការប្រើប្រាស់ធនធានមានប្រសិទ្ធភាពខ្ពស់ តាមរយៈការតម្រង់ទិសធនធានឆ្ពោះទៅកាន់តំបន់ជនបទ ឬតំបន់ដែលមានសេវាសុខាភិបាលនៅមានកម្រិត ដើម្បីកាត់បន្ថយគម្លាតនៃការទទួលបានសេវាថែទាំសុខភាព និងលើកកម្ពស់សមធម៌សុខភាព ព្រមទាំងជាមគ្គុទេសក៏សម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្នុងកសាងមូលដ្ឋានសុខាភិបាលថ្មីឱ្យស្របតាមតម្រូវការសុខភាពជាក់ស្តែង ទំហំតម្រូវការសេវា មានប្រសិទ្ធភាពចំណាយខ្ពស់ និងមានចីរភាព ក្នុងបរិបទធនធានមានកម្រិត។

## ផែនការសកម្មភាព

### វិសាលភាពផែនការ និងគម្រោងវិនិយោគ

៩ គាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាល ២០២៥-២០៣៤ ឱ្យទទួលបានជោគជ័យ ដើម្បីសម្រេចចក្ខុវិស័យសុខភាព ក្នុងការរួមចំណែកអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងកម្មវិធីអាទិភាពទី១។

១០ គាំទ្រដល់ការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាល តាមរយៈការពង្រឹង និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល ពិសេស មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកថ្នាក់ស្រុក ដើម្បីធានាដល់ការចូលមកទទួលយកសេវារបស់ប្រជាជនមានភាពងាយស្រួល និងបង្កើនសមត្ថភាពផ្តល់សេវាសុខភាពបានពេញលេញ មានគុណភាព ចីរភាព និងបរិយាបន្ន ជាពិសេស នៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល។

១១ **គម្រោងវិនិយោគ**ថវិកាជាតិលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់ក្រសួងសុខាភិបាល ឆ្នាំ២០២៦-២០២៩ មានប្រមាណ ២៣៩ ៨៨៩លានរៀល និងគម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល ក្នុងការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឆ្នាំ២០២២-២០២៧ មានប្រមាណ ២០លានដុល្លារអាមេរិក។

## ការព្យាករណ៍ចំនួនមូលដ្ឋានសុខាភិបាលនៅឆ្នាំ២០៣០

១២ តាមការព្យាករណ៍ ប្រជាជនកម្ពុជានឹងកើនដល់ ២២ លាននាក់ នៅដំណាច់ឆ្នាំ២០៥០ (ឆ្នាំ២០៣០ ប៉ាន់ប្រមាណចំនួន ១៨ ៧៣៥ ៩៧៧នាក់) ហើយរចនាសម្ព័ន្ធ អាយុក៏នឹងផ្លាស់ប្តូរទៅតាមនោះដែរ ក្នុងនោះប្រជាជនអាយុលើសពី ៦០ឆ្នាំ នឹងកើនលើសពី ២៣% នៃប្រជាជនសរុប។

១៣ តាមនិន្នាការកំណើនប្រជាជនប្រចាំឆ្នាំ និងតាមទិន្នន័យឆ្នាំ២០២៥ ដែលមណ្ឌលសុខភាព ១ បម្រើប្រជាជនចំនួន ១៣ ៤០០នាក់ ការព្យាករណ៍ចំនួនមណ្ឌលសុខភាពអាចកើនដល់ ១ ៣៩៦ នៅឆ្នាំ២០៣០ ដោយត្រូវបង្កើត/ដំឡើងមណ្ឌលសុខភាពថ្មីក្នុងរយៈពេល៥ឆ្នាំទៅមុខចំនួន ៩១ កន្លែង និងជាមធ្យមក្នុងមួយឆ្នាំ ១៨ កន្លែង។ គិតជាសមាមាត្រនៃការគ្របដណ្តប់ឃុំ/សង្កាត់ មណ្ឌលសុខភាព ១ គ្របដណ្តប់ប្រហាក់ប្រហែល ១ ឃុំ/សង្កាត់ (១,២) ដែលស្របនឹងគោលនយោបាយ ឃុំ ១ មានមណ្ឌលសុខភាព ១។

១៤ ការដំឡើងមន្ទីរពេទ្យបង្អែកកម្រិត១ ពីមណ្ឌលសុខភាពមានគ្រែដែលជាពេទ្យស្រុកចាស់ និងមានចំនួនប្រជាជនគ្របដណ្តប់សមស្រប ដើម្បីបង្ខិតសេវាសុខភាពកម្រិតបង្អែកឱ្យជិតប្រជាជន និងស្របតាមព្រំដែនរដ្ឋបាលស្រុកក្នុងបរិបទគោលនយោបាយវិមជ្ឈការ ព្រមទាំងបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាពដល់រដ្ឋបាលមូលដ្ឋាន។ ផ្ទុយទៅវិញ ចំនួនមន្ទីរពេទ្យបង្អែកស្រុក ក្នុងខេត្តនីមួយៗ មិនគួរបង្កើតឱ្យលើសចំនួនស្រុករដ្ឋបាលដែលមាននៅក្នុងខេត្តនីមួយៗឡើយ ក្នុងកំឡុងពេលឆ្នាំ២០៣០។

១៥ នៅតាមបណ្ដាទីប្រជុំជនក្នុងទីរួមខេត្ត និងរាជធានីភ្នំពេញ ការបង្កើតមណ្ឌលសុខភាពថ្មីមិនមែនជាអាទិភាពចាំបាច់ ដោយសារ ភូមិសាស្ត្រនៃការចូលមកទទួលសេវារបស់ប្រជាជនមិនមែនជាឧបសគ្គ ហើយជាទីកន្លែងដែលមានការផ្ដល់សេវាសំបូរបែប ពីមន្ទីរពេទ្យជាតិ មន្ទីរពេទ្យខេត្ត និងសេវាឯកជន ក្នុងករណីនេះ ការពង្រឹងគុណភាពសេវា និងសុវត្ថិភាពអ្នកជំងឺជាការចាំបាច់បំផុត។ ទន្ទឹមនឹងនេះ ក្នុងរយៈពេល៥ឆ្នាំខាងមុខ ខេត្តតូចមួយចំនួនដែលមានប្រជាជនតិច មិនគួរអនុញ្ញាតឱ្យបង្កើតមណ្ឌលសុខភាពថ្មីបន្ថែមទៀតដែរ។

១៦ តាមកំណើនប្រជាជន ស្ថានភាពភូមិសាស្ត្រចូលមកទទួលសេវាសុខភាព ផែនការដែលបានលើកដោយមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត និងតាមលទ្ធភាពធនធានដែលអាចមាន ផែនការអភិវឌ្ឍន៍មូលដ្ឋានសុខាភិបាលរូបវន្ត ៥ឆ្នាំ (២០២៦-២០៣០) របស់ក្រសួងសុខាភិបាល បានកំណត់ចំនួនមណ្ឌលសុខភាព (បង្កើតថ្មី/ដំឡើងពីប៉ុស្តិ៍សុខភាព) ៩១កន្លែង ចំនួនមន្ទីរពេទ្យបង្អែកកម្រិត១ (បង្កើតថ្មី/ដំឡើងពីមណ្ឌលសុខភាពមានគ្រែដែលជាអតីតពេទ្យស្រុក) ១១កន្លែង ចំនួនមន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) ១៥កន្លែង និងចំនួនមន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) ២កន្លែង ព្រមទាំង ចំនួនការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ (បង្កើតថ្មី) ៦។

១៧ តាមកំណើននៃមូលដ្ឋានសុខាភិបាលដែលនឹងបង្កើតថ្មី និងដំឡើងត្រឹមឆ្នាំ ២០៣០ តម្រូវការបុគ្គលិកសុខាភិបាលបន្ថែម ចំនួនសរុប ១ ៥៩០នាក់ ក្នុងនោះតម្រូវការសម្រាប់ឆ្នាំ២០២៦ ចំនួន ៥១៦នាក់ ឆ្នាំ២០២៧ ចំនួន ៣០៨នាក់ ឆ្នាំ២០២៨ ចំនួន ២៦២នាក់ ឆ្នាំ២០២៩ ចំនួន ២៨២នាក់ និងឆ្នាំ២០៣០ ចំនួន ២២២នាក់។ ក្នុងចំណោមនោះ បុគ្គលិកត្រូវបែងចែកតាមតម្រូវការនៅមណ្ឌលសុខភាពចំនួន ៦៤៥នាក់ ប៉ុស្តិ៍សុខភាពចំនួន ៣០នាក់ មន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ៣២៤នាក់ មន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ៤៥០នាក់ និងមន្ទីរពេទ្យបង្អែកកម្រិត៣ ចំនួន ៦០នាក់។

## ការអនុវត្ត ការតាមដាន និងការវាយតម្លៃ

១៨ ស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំផែនការសកម្មភាព-ថវិកាប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិកាជាមួយគម្រោងចំណាយ។ ក្នុងការគាំទ្រដល់ការអនុវត្ត នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល ត្រូវរៀបចំគោលការណ៍ ស្ដីពីដំណើរការ និងនីតិវិធីនៃការរៀបចំគម្រោងស្នើសុំបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាល និងផ្សព្វផ្សាយដល់អង្គភាពសុខាភិបាលពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងដៃគូសុខាភិបាល។

# មាតិកា


**អារម្ភកថា** ______ i

**ខ្លឹមសារសង្ខេប** ______ iii

**១ សេចក្តីផ្តើម** ______ **១**

១.១-សារបាន ២

១.២-បែបបទរៀបចំផែនការ ៣

១.៣-ស្ថានភាពបច្ចុប្បន្ន ៤

១.៣.១ សមិទ្ធផលនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល ៤

១.៣.២ សន្និទានកម្ម ៨

១.៣.៣ បញ្ហាប្រឈម ១១

១.៣.៤ អាទិភាពសម្រាប់ឆ្នាំ២០២៦-២០៣០ ១២

**២ គោលដៅនៃផែនការអភិវឌ្ឍន៍** ______ **១៣**

**៣ ផែនការសកម្មភាព** ______ **១៥**

៣.១- វិសាលភាពនៃផែនការអភិវឌ្ឍន៍ ១៦

៣.២- ការព្យាករណ៍ និងប៉ាន់ស្មានចំនួនមូលដ្ឋានសុខាភិបាលឆ្នាំ២០២៦-២០៣០ ក្នុងវិស័យសុខាភិបាល ១៧

៣.៣- ការព្យាករណ៍ និងប៉ាន់ស្មានចំនួនមូលដ្ឋានសុខាភិបាលតាមរាជធានី ខេត្ត ពីឆ្នាំ២០២៦-២០៣០ ២០

៣.៤- តម្រូវការធនធាន ៥៦

**៤ ការអនុវត្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃ** ______ **៥៩**

**៥ សេចក្តីសន្និដ្ឋាន** ______ **៦១**


មណ្ឌលសុខភាពអូរឬស្សី ១
O'russey Health Center I

# ១

# សេចក្តីផ្តើម



យោងតាមអង្គការសុខភាពពិភពលោក ប្រព័ន្ធសុខាភិបាលគ្របដណ្តប់យ៉ាងទូលាយលើស្ថាប័នមនុស្ស និងសកម្មភាពជាច្រើន ហើយបំណងប្រាថ្នាបឋម គឺលើកកម្ពស់ស្តារ ឬរក្សាសុខភាព ដែលពាក់ព័ន្ធនឹងមុខងារជាច្រើន ដូចជា ការរៀបចំចាត់ចែងស្ថាប័ន ការគ្រប់គ្រងហិរញ្ញប្បទាន ការកៀងគរ និងការវិភាជធនធាន ដើម្បីផ្តល់សេវាសុខភាពដែលឆ្លើយតបនឹងតម្រូវការផ្នែកសុខភាពរបស់ប្រជាជន។

## ១.១-សារបាន

ក្រសួងសុខាភិបាលបានចាប់ផ្តើមអនុវត្តការកែទម្រង់វិស័យសុខាភិបាល កាលពីឆ្នាំ១៩៩៥ ក្នុងគោលដៅចម្បង «លើកកម្ពស់ និងពង្រីកការថែទាំសុខភាពបឋម តាមរយៈការអនុវត្តអភិក្រមប្រព័ន្ធសុខាភិបាលស្រុកប្រតិបត្តិ» ដើម្បីឆ្លើយតបនឹងតម្រូវការសុខភាពសារវន្ត និងកសាងទំនុកចិត្តប្រជាជនមកលើប្រព័ន្ធសុខាភិបាល។ កំណែទម្រង់នេះតម្រូវឱ្យធ្វើបរិវត្តកម្មទាំងរចនាសម្ព័ន្ធ និងហិរញ្ញប្បទានសុខាភិបាល។ ការធ្វើបរិវត្តកម្មរចនាសម្ព័ន្ធ បានផ្លាស់ប្តូរនិម្មាបនកម្មប្រព័ន្ធសុខាភិបាលដែលផ្អែកលើរចនាសម្ព័ន្ធរដ្ឋបាល (ឃុំមួយមានគិលានដ្ឋានឃុំមួយ ស្រុកមួយមានមន្ទីរពេទ្យមួយ) ទៅកាន់ប្រព័ន្ធសុខាភិបាលដែលផ្អែកលើប្រជាជន ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យដែលបានកំណត់ សម្រាប់ការបង្កើតមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក។ ការកែទម្រង់វិស័យសុខាភិបាលបាននាំមកនូវការផ្លាស់ប្តូរជាសារវន្តតាមរយៈ៖

- រចនាបថនិម្មាបនកម្មរចនាសម្ព័ន្ធប្រព័ន្ធសុខាភិបាលឡើងវិញ និងកំណត់ច្បាស់លាស់សាជាថ្មីនូវតួនាទី និងប្រភេទសេវាថែទាំសុខភាពដែលត្រូវផ្តល់ថ្នាក់នីមួយៗ នៅក្នុងប្រព័ន្ធសុខាភិបាល។
- បង្កើតតំបន់ទទួលខុសត្រូវសម្រាប់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ដើម្បីធានាការគ្របដណ្តប់ពេញលេញលើប្រជាជន ដោយគ្មានចន្លោះប្រហោង និងគ្មានការត្រួតជាន់គ្នា ដោយប្រើលក្ខណៈវិនិច្ឆ័យ **«ចំនួនប្រជាជន និងស្ថានភាពភូមិសាស្ត្រចូលទៅរកសេវា»**។
- ធ្វើបរិវត្តកម្មវិកានីយកម្ម សំដៅលើកកម្ពស់ការវិភាជ និងការប្រើប្រាស់ធនធានប្រកបដោយសនិទានភាព ការបែងចែក និងការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាលឡើងវិញ។
- ដាក់ចេញនូវមធ្យោបាយហិរញ្ញប្បទានសេវាសុខាភិបាល រួមមាន៖ (ការអនុវត្តការបង់ថ្លៃសេវា ភ្ជាប់ជាមួយគោលនយោបាយលើកលែងការបង់ថ្លៃសម្រាប់ប្រជាជនក្រីក្រ និងងាយរងគ្រោះ ការគ្រប់គ្រងសេវាសុខាភិបាលបែបនវានុវត្តន៍ (ដូចជាការអនុវត្តអភិក្រមកិច្ចសន្យាផ្តល់សេវាសុខាភិបាល ទីភ្នាក់ងារប្រតិបត្តិការពិសេស) និងការត្រួសត្រាយផ្លូវសម្រាប់ការអភិវឌ្ឍការធានារ៉ាប់រងសុខភាពសង្គម ដូចជាការអនុវត្តគម្រោងធានារ៉ាប់រងសុខភាពតាមសហគមន៍ មូលនិធិសមធម៌សុខាភិបាលជាដើម។

បច្ចុប្បន្ននេះ កម្ពុជាទទួលបានជោគជ័យ និងសមិទ្ធផលធំធេងគួរឱ្យកត់សំគាល់ ក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជារូបវន្តរបស់មូលដ្ឋានសុខាភិបាលសាធារណៈ (ជាពិសេស មណ្ឌលសុខភាពត្រូវបានសាងសង់តាមគំរូស្តង់ដាក្រសួងសុខាភិបាល) ដែលមានតួនាទីជាមូលដ្ឋានគ្រឹះដ៏សំខាន់ដើម្បីធានាដល់ការផ្តល់សេវាសុខភាពសាធារណៈដល់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរ នៅក្នុងអំឡុងពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ។ ទោះជាយ៉ាងណា នៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវបានកត់សម្គាល់ ដូចជាការពង្រាយមូលដ្ឋានសុខាភិបាលសាធារណៈនៅទូទាំងប្រទេសមិនទាន់មានសមធម៌ និងមូលដ្ឋានសុខាភិបាលជាច្រើននៅតំបន់ជនបទ ឬខេត្តដាច់ស្រយាល នៅតែប្រឈមនឹងបញ្ហាហេដ្ឋារចនាសម្ព័ន្ធចាស់ អគារមិនគ្រប់គ្រាន់ ឬមិនសមស្របទៅនឹងតម្រូវការជាក់ស្តែងនៃសេវាសុខភាពរបស់ប្រជាពលរដ្ឋ។

## ១.២-បែបបទរៀបចំផែនការ

ផែនការការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល មានរយៈពេល ៥ឆ្នាំ គិតចាប់ពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០ ត្រូវបានរៀបចំឡើងក្រោមការផ្តល់ការណែនាំ និងតម្រង់ទិសជាយុទ្ធសាស្ត្រពីថ្នាក់ដឹកនាំក្រសួងសុខាភិបាល និងថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន។ ក្រុមការងារអន្តរនាយកដ្ឋាន និងនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាលបានសហការ និងសម្របសម្រួលកិច្ចដំណើរការរៀបចំផែនការអភិវឌ្ឍន៍ ក្រោមការគាំទ្រថវិកាពីប្រព័ន្ធលើកទឹកចិត្តសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល និងគាំទ្របច្ចេកទេសពីទីប្រឹក្សាគោលនយោបាយរបស់អង្គការ JICA។

ការកសាងផែនការអភិវឌ្ឍន៍ បានផ្អែកតាមគោលនយោបាយកំណែទម្រង់សុខាភិបាល សេចក្តីណែនាំអភិវឌ្ឍន៍ស្រុកប្រតិបត្តិឆ្នាំ១៩៩៨ សេចក្តីណែនាំសំណុំសកម្មភាពអប្បបរមាឆ្នាំ២០១៨ សេចក្តីណែនាំសំណុំសកម្មភាពបង្គ្រប់ឆ្នាំ២០១៤ និងផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ២០២៥-២០៣៤។ ទន្ទឹមនឹងនេះ ផែនការក៏បានមកពីការសំយោគផែនការសកម្មភាព និងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរសុខា-ភិបាល នៃរដ្ឋបាលរាជធានី ខេត្ត ជាពិសេស ផែនការវិនិយោគរបស់ក្រសួងសុខាភិបាល។

ការប្រព្រឹត្តទៅនៃការបង្កើតផែនការអភិវឌ្ឍន៍ ឆ្នាំ២០២៦-២០៣០ ជាតម្រូវការចាំបាច់សម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្នុងការគ្រប់គ្រងការអភិវឌ្ឍមូលដ្ឋានសុខាភិបាលប្រកបដោយប្រសិទ្ធភាពចំណាយ ការកៀរគរធនធានបន្ថែម ការសម្រួចអាទិភាព និងការឆ្លើយតបនឹងតម្រូវការសុខភាពសារវន្តរបស់ប្រជាពលរដ្ឋតាមភូមិសាស្ត្ររស់នៅ។

## ១.៣-ស្ថានភាពបច្ចុប្បន្ន

ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនាពេលកន្លងមកដល់បច្ចុប្បន្ន របស់ក្រសួងសុខាភិបាល បានផ្តោតលើតម្រូវការជាក់ស្តែងតាមបណ្តារាជធានី ខេត្ត ផ្អែកតាមផែនការគ្របដណ្តប់សុខាភិបាល និងតាមការគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងការសាងសង់អគារនៃមូលដ្ឋានសុខាភិបាលពីដៃគូសុខាភិបាល និងសប្បុរសជនជាដើម។

### ១.៣.១ សមិទ្ធផលនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល

ការវិនិយោគលើការពង្រឹង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធនិងសេវាសុខាភិបាល មានភាពល្អប្រសើរជាលំដាប់ ដោយបានបង្ហាញថា រវាងឆ្នាំ២០១៦ ដល់ឆ្នាំ២០២៥ មូលដ្ឋានសុខាភិបាលបានកើនឡើង ១៤,០% គឺពី ១ ៣៧១ កន្លែង នៅឆ្នាំ២០១៦ ដល់ ១ ៥៦៣ កន្លែង នៅឆ្នាំ២០២៥ ស្របនឹងកំណើនប្រជាជន ១២,៥% គឺពី ១៥ ៦២៦ ៤៤៤ នាក់ នៅឆ្នាំ២០១៦ ទៅ ១៧ ៥៧៧ ៧៥៩ នាក់ នៅឆ្នាំ២០២៥។ បើគិតជាសមាមាត្រនៃការបម្រើប្រជាជនជាមធ្យម របស់មណ្ឌលសុខភាពមួយមានចំនួន ១៣ ៤២៤ នាក់ នៅឆ្នាំ២០១៦ មក ១៣ ៤០៧ នាក់ នៅឆ្នាំ២០២៥ ដែលចំនួននេះ ប្រហាក់ប្រហែលនឹងនិយាមស្តង់ដានៃការគ្របដណ្តប់ប្រជាជនរបស់មណ្ឌលសុខភាព។

គិតត្រឹមខែធ្នូ ឆ្នាំ២០២៥ មូលដ្ឋានសុខាភិបាលទូទាំងប្រទេសមានចំនួនសរុប ១ ៥៦៣ ក្នុងនោះ មន្ទីរពេទ្យជាតិ ១២ មន្ទីរពេទ្យបង្អែកខេត្ត ២៥ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ចំនួន ៩៩ មណ្ឌលសុខភាព ១ ៣១១ (មណ្ឌលសុខភាពមានគ្រែ ៦៦ និងគ្មានគ្រែ ១ ២៤៥) និងប៉ុស្តិ៍សុខភាព ១១៦ (មិនរាប់បញ្ចូលប៉ុស្តិ៍សុខភាពពន្ធនាគារ ១៦) តារាង ១ បង្ហាញពីស្ថិតិមូលដ្ឋានសុខាភិបាលតាមរាជធានី ខេត្ត ឆ្នាំ២០២៥។

### តារាង ១ ស្ថិតិមូលដ្ឋានសុខាភិបាលតាមរាជធានី ខេត្ត ឆ្នាំ២០២៥

| ល.រ | រាជធានី-ខេត្ត | ក្រុង/ស្រុក/ខណ្ឌ | ចំនួន ប្រជាជន | ឃុំ/សង្កាត់ | ស្រុកប្រតិបត្តិ | មន្ទីរពេទ្យបង្អែក | | | | មណ្ឌលសុខភាព | | | ប៉ុស្តិ៍សុខភាព ប្រ.ទូទៅ | ប៉ុស្តិ៍សុខភាពពន្ធនាគារ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | សរុប | CPA3 | CPA2 | CPA1 | សរុប | មានគ្រែ | គ្មានគ្រែ | | |
| ១ | បន្ទាយមានជ័យ | 9 | 974,136 | 67 | 6 | 9 | 1 | 3 | 5 | 68 | - | 68 | 14 | 1 |
| ២ | បាត់ដំបង | 14 | 1,127,042 | 103 | 5 | 9 | 1 | 2 | 6 | 82 | 5 | 77 | 1 | 1 |
| ៣ | កំពង់ចាម | 10 | 1,016,981 | 109 | 9 | 9 | 1 | 4 | 4 | 96 | - | 96 | 4 | 1 |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤ | កំពង់ឆ្នាំង | 8 | 595,668 | 71 | 3 | 3 | 1 | - | 2 | 45 | 3 | 42 | 1 | 1 |
| ៥ | កំពង់ស្ពឺ | 8 | 991,813 | 88 | 4 | 4 | 1 | 2 | 1 | 62 | 2 | 60 | 3 | 1 |
| ៦ | កំពង់ធំ | 9 | 770,315 | 81 | 3 | 3 | 1 | 2 | - | 56 | 5 | 51 | 5 | - |
| ៧ | កំពត | 9 | 671,170 | 93 | 4 | 5 | 1 | 3 | 1 | 66 | 3 | 63 | 1 | - |
| ៨ | កណ្តាល | 13 | 1,358,077 | 127 | 10 | 11 | 2 | 2 | 7 | 107 | 9 | 98 | 3 | 1 |
| ៩ | កោះកុង | 7 | 142,300 | 29 | 2 | 2 | - | 1 | 1 | 15 | 4 | 11 | 11 | 1 |
| ១០ | ក្រចេះ | 7 | 423,564 | 48 | 4 | 5 | 1 | 1 | 3 | 41 | - | 41 | 13 | - |
| ១១ | មណ្ឌលគិរី | 5 | 104,223 | 21 | 1 | 3 | - | 1 | 2 | 16 | 4 | 12 | 11 | - |
| ១២ | ភ្នំពេញ | 14 | 2,579,157 | 105 | 7 | 9 | 1 | - | 8 | 46 | - | 46 | 5 | - |
| ១៣ | ព្រះវិហារ | 8 | 288,016 | 51 | 1 | 2 | 1 | - | 1 | 30 | 16 | 14 | 15 | - |
| ១៤ | ព្រៃវែង | 13 | 1,195,479 | 116 | 12 | 12 | 1 | 3 | 8 | 113 | 2 | 111 | 6 | 1 |
| ១៥ | ពោធិ៍សាត់ | 7 | 474,647 | 49 | 4 | 5 | 1 | - | 4 | 47 | - | 47 | 1 | 2 |
| ១៦ | រតនគិរី | 9 | 245,774 | 50 | 2 | 3 | 1 | 1 | 1 | 29 | 6 | 23 | 6 | 1 |
| ១៧ | សៀមរាប | 13 | 1,146,330 | 100 | 4 | 6 | 1 | 4 | 1 | 93 | 4 | 89 | 1 | 1 |
| ១៨ | ព្រះសីហនុ | 6 | 350,456 | 29 | 1 | 1 | 1 | - | - | 18 | - | 18 | 3 | 1 |
| ១៩ | ស្ទឹងត្រែង | 6 | 187,296 | 34 | 1 | 1 | 1 | - | - | 22 | 2 | 20 | 6 | - |
| ២០ | ស្វាយរៀង | 8 | 593,939 | 80 | 4 | 6 | 1 | 1 | 4 | 49 | - | 49 | 1 | 1 |
| ២១ | តាកែវ | 10 | 1,018,251 | 100 | 6 | 7 | 1 | 2 | 4 | 84 | 1 | 83 | 2 | 1 |
| ២២ | ឧត្តមានជ័យ | 5 | 311,990 | 24 | 2 | 2 | 1 | - | 1 | 39 | - | 39 | 1 | - |
| ២៣ | កែប | 2 | 48,222 | 5 | 1 | 1 | - | 1 | - | 5 | - | 5 | - | - |
| ២៤ | ប៉ៃលិន | 2 | 84,895 | 8 | 1 | 1 | - | 1 | - | 7 | - | 7 | - | 1 |
| ២៥ | ត្បូងឃ្មុំ | 7 | 878,018 | 64 | 7 | 7 | 1 | 4 | 2 | 75 | - | 75 | 1 | - |
| ២៦ | មន្ទីរពេទ្យជាតិ | | | | | 12 | | | | | | | | |
| | **សរុប** | **209** | **17,577,759** | **1,652** | **104** | **138** | **22** | **38** | **66** | **1,311** | **66** | **1,245** | **115** | **16** |

ការកើនឡើងនៃមូលដ្ឋានសុខាភិបាល ត្រូវបានផ្សារភ្ជាប់ទៅនឹងកំណើនរបស់ប្រជាពលរដ្ឋគ្របដណ្តប់ និងតម្រូវការសេវាសុខាភិបាលជាក់ស្តែងក្នុងតំបន់ ដែលត្រូវអនុញ្ញាតិឱ្យបង្កើត ឬដំឡើងកម្រិតមូលដ្ឋានសុខាភិបាល ដោយផ្អែកលើគោលការណ៍ចំនួន២៖ ១)ផ្អែកលើចំនួនប្រជាជន ២)ផ្អែកលើលក្ខណៈភូមិសាស្ត្រចូលទៅរកសេវា ដែលបានកំណត់តាំងពីឆ្នាំ១៩៩៥ (តារាង១ បង្ហាញពីលក្ខណៈវិនិច្ឆ័យបង្កើតមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក)។ ទន្ទឹមនឹងនេះ មានកត្តាផ្សេងៗទៀត ក៏ត្រូវបានទទួលយកមកពិចារណាផងដែរ ក្នុងការបង្កើត ឬដំឡើងកម្រិតមូលដ្ឋានសុខាភិបាល រួមមាន សំណូមពររបស់ប្រជាពលរដ្ឋ ឬអាជ្ញាធរមូលដ្ឋានតាមរយៈវេទិកាសាធារណៈ ក្រុមការងារចុះមូលដ្ឋាន សប្បុរសជន ដៃគូអភិវឌ្ឍន៍ និងគម្រោងផ្សេងៗ។ ការណ៍នេះ បណ្តាលឱ្យការអភិវឌ្ឍប្រកបដោយដុំ ឬទៅតាមតំបន់ មិនបានពង្រាយស្របតាមការគ្របដណ្តប់ប្រជាជន។

### តារាង ២. លក្ខណៈវិនិច្ឆ័យបង្កើតមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកនៅឆ្នាំ១៩៩៥

| | ចំនួនប្រជាជន (នាក់) | លក្ខណៈភូមិសាស្ត្រចូលទៅរកសេវា |
|---|---|---|
| **មណ្ឌលសុខភាព** | សមស្របបំផុត ១០ ០០០<br>ប្រែប្រួលពី ៨ ០០០-១២ ០០០ | តំបន់ទទួលខុសត្រូវក្នុងរង្វង់ ១០គ.ម ឬធ្វើដំណើរថ្មើរ ជើង ១ម៉ោងទៅកាន់មណ្ឌលសុខភាព |
| • តំបន់ដង់ស៊ីតេប្រជាជនខ្ពស់ | ២០ ០០០ | លក្ខណៈវិនិច្ឆ័យនេះមិនពាក់ព័ន្ធ ដោយសារគ្មានបញ្ហាក្នុងការចូលមករកសេវា និងសេវាសុខាភិបាលឯកជនមានច្រើន |
| • តំបន់ដង់ស៊ីតេប្រជាជនខ្ពស់<br>**ប៉ុស្តិ៍សុខភាព** | យ៉ាងតិច ៣ ០០០ | លើសពី១៥គ.ម.ពីមណ្ឌលសុខភាពដែលនៅជិតបំផុត និង/ឬ មានឧបសគ្គភូមិសាស្ត្រ (ទន្លេ ភ្នំ ផ្លូវពិបាក ក្នុងរដូវវស្សា) |
| **មន្ទីរពេទ្យបង្អែក** | សមស្របបំផុត ១០០ ០០០<br>ប្រែប្រួលពី ៨០ ០០០- ២០០ ០០០ | តំបន់ទទួលខុសត្រូវ ៣០-៤០គ.ម ឬ ធ្វើដំណើរ ២ម៉ោងដោយរថយន្ត ឬ កាណូតទៅកាន់មន្ទីរពេទ្យ |
| **ការិយាល័យស្រុកប្រតិបត្តិ** | ១៣០ ០០០-២៥០ ០០០ | គ្របដណ្តប់ស្រុករដ្ឋបាលយ៉ាងតិចមួយ មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព និង អាចមានមន្ទីរពេទ្យបង្អែក១ |

ក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ (២០២៣-២០២៥) មូលដ្ឋានសុខាភិបាលសាធារណៈត្រូវបានបង្កើតថ្មី និងដំឡើងកម្រិត សរុបចំនួន ៥២ កន្លែង ដែលជាមធ្យមក្នុងមួយឆ្នាំមូលដ្ឋានសុខាភិបាលបង្កើតថ្មី និងដំឡើងកម្រិតមានចំនួន ១៧ កន្លែង។ ក្នុងចំណោមចំនួនបង្កើតថ្មី និងដំឡើងកម្រិតនេះ មណ្ឌលសុខភាពមានកម្រិតខ្ពស់រហូតដល់ ៥២% និងប៉ុស្តិ៍សុខភាពបង្កើតថ្មី ៣៧%។ ដោយឡែក ក្នុងឆ្នាំ២០២៥ មូលដ្ឋានសុខាភិបាលចំនួន ២១ កន្លែង ត្រូវបានដំឡើងកម្រិត និងបង្កើតថ្មី (បង្កើតស្រុកប្រតិបត្តិថ្មី១ បង្កើតនិងដំឡើងមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ២កន្លែង ដំឡើងពីប៉ុស្តិ៍សុខភាពជាមណ្ឌលសុខភាព ១កន្លែង បង្កើតមណ្ឌលសុខភាពថ្មី ៨ កន្លែង និងបង្កើតប៉ុស្តិ៍សុខភាពថ្មី ៩ កន្លែង)។

ក្នុងរយៈពេលនេះដែរ ក្រសួងសុខាភិបាលបានសាងសង់មូលដ្ឋានសុខាភិបាល រួមមាន អគារមន្ទីរពេទ្យខេត្ត ២កន្លែង អគារមន្ទីរពេទ្យស្រុកកម្រិត៣ ចំនួន ១កន្លែង មន្ទីរពេទ្យបង្អែកស្រុកកម្រិត១ ចំនួន ១កន្លែង មណ្ឌលសុខភាព ៦៧ កន្លែង និងប៉ុស្តិ៍សុខភាព ៦កន្លែង។ ការសាងសង់អគារបន្ថែមក្នុងការិយាល័យស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាលចំនួន ៤ខេត្ត មន្ទីរពេទ្យខេត្ត ៤កន្លែង មន្ទីរពេទ្យបង្អែក ២៣ កន្លែង បន្ថែមបន្ទប់សម្រាល និងក្រោយសម្រាល ១៣ បន្ទប់ ព្រមទាំងជួសជុលកែលម្អដើម្បីពង្រឹងគុណភាពសេវា រួមមានការជួសជុលអគារសង្គ្រោះបន្ទាន់ និងវះកាត់ ៦១ កន្លែង និងអគារមន្ទីរពិសោធន៍ ៥០ កន្លែង ផងដែរ។

**តារាង ៣៖ ស្ថិតិមូលដ្ឋានសុខាភិបាលដែលបានសាងសង់ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តរវាងឆ្នាំ២០២៣-២០២៥**

| ឆ្នាំ | សាងសង់និងជួសជុល |
|---|---|
| ២០២៣ | • សាងសង់មន្ទីរពេទ្យបង្អែកកម្រិត៣ ចំនួន១កន្លែង<br>• សាងសង់មន្ទីរពេទ្យកម្រិត១ ចំនួន១កន្លែង<br>• សាងសង់អគារមណ្ឌលសុខភាព ២១កន្លែង<br>• សាងសង់អគារក្នុងមន្ទីរពេទ្យបង្អែក១៤កន្លែង<br>• សាងសង់អគារប៉ុស្តិ៍សុខភាព៤កន្លែង<br>• សាងសង់បន្ទប់រង់ចាំក្រោយសម្រាល៤បន្ទប់<br>• សំណង់អគារការិយាល័យសុខាភិបាស្រុកប្រតិបត្តិ ក្នុងខេត្តមណ្ឌលគិរី តាកែវ និងរតនៈគិរី<br>• អគាររដ្ឋបាល មន្ទីរសុខាភិបាលខេត្តមណ្ឌលគិរី និងព្រះវិហារ។ |

| | |
|---|---|
| **២០២៤** | • សាងសង់អគារមណ្ឌលសុខភាព ២៥កន្លែង<br>• សាងសង់អគារប៉ុស្តិ៍សុខភាព២៧កន្លែង<br>• បន្ថែមអគារក្នុងមន្ទីរពេទ្យខេត្ត ៨កន្លែង<br>• បន្ថែមអគារក្នុងមន្ទីរពេទ្យបង្អែក៩កន្លែង<br>• សាងសង់អគារក្នុងស្រុកប្រតិបត្តិ ៥កន្លែង<br>• សាងសង់បន្ទប់សម្រាល ៣បន្ទប់<br>• សាងសង់បន្ទប់រង់ចាំក្រោយសម្រាល១០បន្ទប់ |
| **២០២៥** | • សាងសង់អគារមណ្ឌលសុខភាព ២១កន្លែង<br>• សាងសង់អគារទីស្តីការក្រសួងសុខាភិបាល<br>• ជួសជុលកែលម្អអគារសង្គ្រោះបន្ទាន់ និងវះកាត់ ៦១កន្លែង<br>• ជួសជុលកែលម្អអគារមន្ទីរពិសោធន៍ ៥០កន្លែង |

### ១.៣.២ សន្និទានកម្ម

**អនាគតនៃប្រព័ន្ធសុខាភិបាលស្រុកប្រតិបត្តិ**

លទ្ធផលនៃការសម្របខ្លួនតាមបរិបទវិវត្តក្នុងអំឡុងបួនទសវត្សរ៍កន្លងមកនេះ បានធ្វើឱ្យប្រព័ន្ធសុខាភិបាលស្រុកប្រតិបត្តិមានលក្ខណៈស្មុគស្មាញ ដែលបច្ចុប្បន្ននេះមានដល់ ៥ ប្រភេទ។ ការណ៍នេះកំពុងនាំមកនូវភាពប្រឈមដល់ដំណើរការរិមជ្ឈការ និងវិសហមជ្ឈការ នៅពេលដែលមុខងារគ្រប់គ្រង និងមុខងារផ្តល់សេវាសុខាភិបាល ត្រូវបានផ្ទេរមួយដំណាក់កាលទៀត ពីរដ្ឋបាលរាជធានី ខេត្ត ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ការវិភាគបានប្រមើលឃើញថាប្រព័ន្ធសុខាភិបាលស្រុកប្រតិបត្តិអាចមានតែ ២ ប្រភេទប៉ុណ្ណោះ នៅក្នុងរយៈពេលវែង៖ **ស្រុកប្រតិបត្តិ A** គ្របដណ្តប់ស្រុករដ្ឋបាលមួយ មានការិយាល័យស្រុកប្រតិបត្តិមួយ មន្ទីរពេទ្យបង្អែកមួយ និងមណ្ឌលសុខភាពមួយគ្របដណ្តប់ឃុំ ឬសង្កាត់មួយ និង **ស្រុកប្រតិបត្តិ B** គ្របដណ្តប់ស្រុករដ្ឋបាលមួយ មានការិយាល័យស្រុកប្រតិបត្តិមួយ ប៉ុន្តែគ្មានមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពមួយគ្របដណ្តប់លើសពីមួយឃុំ។ ស្រុកប្រតិបត្តិ**ប្រភេទ B** ស័ក្តិសមបំផុតសម្រាប់តំបន់ទីក្រុង និងតំបន់ប្រជុំជន ដោយហេតុថាមិនមានឧបសគ្គភូមិសាស្ត្រ ក្នុងការចូលទៅរកសេវា ហើយអ្នកផ្តល់សេវាសុខាភិបាលឯកជនមានច្រើនកុះករ។

## រូបបំព្រួញ ១៖ មាគ៌ាឆ្ពោះទៅកាន់ប្រព័ន្ធសុខាភិបាលស្រុកប្រតិបត្តិក្នុងពេលអនាគត

**១៩៩៥-២០២៤** → **២០២៥-២០៣០** → **ក្រោយឆ្នាំ២០៣០**

**A** ស្រុកប្រតិបត្តិ ១ ស្រុករដ្ឋបាល១ ការិយាល័យស្រុកប្រតិបត្តិ ១ មន្ទីរពេទ្យបង្អែក ១

**B** ស្រុកប្រតិបត្តិ ១ ស្រុករដ្ឋបាល១ ការិយាល័យស្រុកប្រតិបត្តិ ១ គ្មានមន្ទីរពេទ្យបង្អែក

**C** ស្រុកប្រតិបត្តិ ១ ស្រុករដ្ឋបាល >១ ការិយាល័យស្រុកប្រតិបត្តិ ១ មន្ទីរពេទ្យបង្អែក ១

**D** ស្រុកប្រតិបត្តិ ១ ស្រុករដ្ឋបាល >១ ការិយាល័យស្រុកប្រតិបត្តិ ១ គ្មានមន្ទីរពេទ្យបង្អែក

**E** ស្រុកប្រតិបត្តិ ១ ស្រុករដ្ឋបាល >១ ការិយាល័យស្រុកប្រតិបត្តិ ១ មន្ទីរពេទ្យបង្អែក២

តម្រៀបបណ្តើរៗតំបន់ទទួលខុសត្រូវរបស់ស្រុកប្រតិបត្តិ ជាមួយព្រំប្រទល់ស្រុករដ្ឋបាល និងតំបន់ទទួលខុសត្រូវរបស់មណ្ឌលសុខភាពជាមួយព្រំប្រទល់ឃុំ ឬសង្កាត់




**កត្តាជំរុញ៖** ប្រជាជនបន្តកើនឡើង និងមានធនធានកាន់តែច្រើន តាមពេលវេលា។ ទោះជាដូច្នេះក្តី ការបង្កើតមណ្ឌល-សុខភាពថ្មី និងមន្ទីរពេទ្យបង្អែកថ្មី ត្រូវពិចារណាពីប្រសិទ្ធភាពប្រព័ន្ធសុខាភិបាល និងផលចំណេញសេដ្ឋកិច្ចដែលនឹងទទួល បានមកវិញពីការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងលើធនធានមនុស្ស ព្រមទាំងសក្តានុពលភាពនៃសេវាឯកជន។

- **ពីរយៈពេលខ្លីទៅរយៈពេលមធ្យម(២០២៤-២០៣០)៖ លក្ខណៈវិនិច្ឆ័យទាំងពីរ** នៅតែមានភាពសមស្របបើយោងតាមនិន្នាការកំណើនប្រជាជន ធនធាននៅមានកម្រិត មណ្ឌលសុខភាពនិងមន្ទីរពេទ្យស្រុកជាច្រើនមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាពេញលេញ ស្របតាមសំណុំសកម្មភាព MPA និង CPA ដែលបានកំណត់។

- **ពីរយៈពេលមធ្យមទៅរយៈពេលវែង(២០៣០-ឆ្នាំបន្ត)៖** លក្ខណៈវិនិច្ឆ័យ **ស្ថានភាពភូមិសាស្ត្រចូលទៅរកសេវា** កាន់តែមិនពាក់ព័ន្ធ ពីព្រោះបណ្ដាញផ្លូវគមនាគមន៍កាន់តែរីកចម្រើន និងមធ្យោបាយធ្វើដំណើរសាធារណៈកាន់តែសម្បូណ៌ ប៉ុន្តែលក្ខណៈវិនិច្ឆ័យ ចំនួនប្រជាជន កាន់តែមានភាពសមស្រប ពីព្រោះ **ចំនួនប្រជាជន**បន្តកើនឡើងតាមកាលវេលា និងធនធានហិរញ្ញវត្ថុមានកាន់តែច្រើន នៅពេលកម្ពុជាសម្រេចឋានៈជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងបន្តឆ្ពោះទៅកាន់ប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។

## របាយមូលដ្ឋានសុខាភិបាលធៀបនឹងចំនួនប្រជាជន

ក្នុងឆ្នាំ២០២៥ ផលធៀបចំនួនមណ្ឌលសុខភាព ១ ៣១១ នឹងចំនួន ឃុំ/សង្កាត់ ១ ៦៥២ បង្ហាញថា មណ្ឌលសុខភាព ១ គ្របដណ្ដប់ ឃុំ/សង្កាត់ ១ ឬ ២ និងបម្រើសេវាថែទាំសុខភាពដល់ប្រជាជនជាមធ្យម ១៣ ៤០៧ នាក់។ របាយនេះមានភាពខុសគ្នាពីខេត្ត ១ ទៅខេត្ត ១ទៀត ជាពិសេស មណ្ឌលសុខភាព ១ បម្រើប្រជាជនច្រើននៅទីប្រជុំជន ដូចជា រាជធានីភ្នំពេញ ក្រុងនៅទីរួមខេត្ត និងទីរួមស្រុក ជាដើម។ ជារួម នៅទីប្រជុំជនមណ្ឌលសុខភាព ១ បម្រើប្រជាជន ពី ៣០ ០០០នាក់ ទៅ ១០០ ០០០នាក់។ ផ្ទុយទៅវិញ នៅតំបន់ជនបទ មណ្ឌលសុខភាព ១ បម្រើប្រជាជន ពី ៦ ០០០នាក់ ទៅ ១៥ ០០០នាក់ និងនៅតំបន់ដាច់ស្រយាល មណ្ឌលសុខភាព ១ បម្រើប្រជាជន ពី ២ ០០០នាក់ ទៅ ៦ ០០០នាក់ និងភាគច្រើនគ្របដណ្ដប់ឃុំលើសពី១។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៥ មណ្ឌលសុខភាពបម្រើប្រជាជនលើសពី ១០ ០០០នាក់ មានចំនួន ៩១៥ បម្រើប្រជាជនពី ៦ ០០០នាក់ ដល់ ១០ ០០០នាក់ មានចំនួន ១២១ និងក្រោម ៦ ០០០នាក់ មានចំនួន ២៧៥។

## ការចំណាយចម្បងៗក្នុងដំណើរការរបស់មូលដ្ឋានសុខាភិបាល

ក្រៅពីការចំណាយវិនិយោគលើការកសាងអគារ និងឧបករណ៍បរិក្ខារធំៗ ការចំណាយប្រតិបត្តិក្នុងដំណើរការផ្តល់សេវាសុខាភិបាលជាប្រចាំ ជាការចាំបាច់បំផុត ក្នុងនោះ បានចំណាយលើបុគ្គលិក (បៀវត្សការកសាងសមត្ថភាព និងការលើកទឹកចិត្ត) ឱសថនិងសម្ភារវេជ្ជសាស្ត្រ ការលើកកម្ពស់គុណភាពសេវា និងចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗទៀត (តារាង ៤៖ ការចំណាយដំណើរការមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកកម្រិត១ មិនរាប់បញ្ចូលការចំណាយប្រតិបត្តិការសកម្មភាព និងរដ្ឋបាលផ្សេងៗ)។

**តារាង ៤៖ ការចំណាយមូលដ្ឋានសម្រាប់ដំណើរការមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកកម្រិត១ (មិនបញ្ចូលការចំណាយសកម្មភាពប្រតិបត្តិការ និងរដ្ឋបាលផ្សេងៗ)**

ឯកតាគិតជារៀល

| ប្រភពចំណាយ | មណ្ឌលសុខភាព (បុគ្គលិក៨នាក់) | មន្ទីរពេទ្យបង្អែកកម្រិត១ (បុគ្គលិក៤៥នាក់) |
|---|---|---|
| បុគ្គលិក (បៀវត្ស) | 153,600,000 | 864,000,000 |
| ឱសថ (ឃីត MPA, CPA) | 169,050,434 | 981,416,240 |
| កញ្ចប់ថវិកាពង្រឹងគុណភាព | 45,000,000 | 530,000,000 |
| សរុប | 367,650,434 | 2,375,416,240 |

### ១.៣.៣ បញ្ហាប្រឈម

- ការអភិវឌ្ឍមូលដ្ឋានសុខាភិបាលនៅតំបន់ជនបទ (ខេត្តដាច់ស្រយាល) នៅមានកម្រិត ដែលនៅតែជាបញ្ហាហេដ្ឋារចនាសម្ព័ន្ធចាស់ៗ មិនទាន់គ្រប់គ្រាន់ ឬមិនទាន់សមស្របទៅនឹងតម្រូវការសេវាសុខភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋ។
- ការពង្រាយមូលដ្ឋានសុខាភិបាល មិនទាន់ស្របតាមរបាយប្រជាជន ដែលបណ្តាលឱ្យមណ្ឌលសុខភាពមួយចំនួន បម្រើប្រជាជនតិចជាង ៤ ០០០នាក់។
- មណ្ឌលសុខភាព និងមន្ទីរពេទ្យស្រុកជាច្រើនមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាពេញលេញស្របតាមសំណុំសកម្មភាពអប្បរមា (MPA) និងសំណុំសកម្មភាពបង្គ្រប់ (CPA) ដែលបានកំណត់។
- នៅតំបន់មួយចំនួន មូលដ្ឋានសុខាភិបាលនៅជិតៗគ្នា បង្កឱ្យប្រសិទ្ធភាពចំណាយទទួលបានផល នៅមានកម្រិត និងការមកទទួលសេវាមានកម្រិតទាប។

### ១.៣.៤ អាទិភាពសម្រាប់ឆ្នាំ២០២៦-២០៣០

ផ្អែកតាមការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តប្រចាំឆ្នាំ តម្រូវការសេវាសុខភាពជាមូលដ្ឋានរបស់ប្រជាជនកើនឡើងស្របតាមការវិវត្តន៍ស្ថានភាពសុខភាពក្នុងតំបន់និងសកល កំណើនប្រជាជន និងគោលនយោបាយជាតិនិងកម្មវិធីអាទិភាពជាតិ ក្រសួងសុខាភិបាលបានកំណត់អាទិភាពចម្បងៗនៃការអភិវឌ្ឍមូលដ្ឋានសុខាភិបាល ដូចខាងក្រោម៖

**ប្រអប់ ១៖ អាទិភាពសម្រាប់អនុវត្តឆ្នាំ២០២៦-២០៣០**

1. **ប្រព័ន្ធស្រុកប្រតិបត្តិនៅតែមានភាពសមស្រប សម្រាប់អភិវឌ្ឍមូលដ្ឋានសុខាភិបាលក្នុងរយៈពេលមធ្យម ២០២៦-២០៣០** ផ្អែកលើកំណើនប្រជាជន ធនធាននៅមានកម្រិត មណ្ឌលសុខភាពនិងមន្ទីរពេទ្យស្រុកជាច្រើនមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាពេញលេញ ស្របតាមសំណុំសកម្មភាពអប្បបរមា ( MPA ) និងសំណុំសកម្មភាពបង្គ្រប់ ( CPA ) ដែលបានកំណត់
2. **តម្រៀបបណ្តើរៗតំបន់ទទួលខុសត្រូវរបស់ស្រុកប្រតិបត្តិជាមួយព្រំប្រទល់ស្រុករដ្ឋបាល និងតំបន់ទទួលខុសត្រូវរបស់មណ្ឌលសុខភាពជាមួយព្រំប្រទល់ឃុំ ឬសង្កាត់**
3. **ការបង្កើតមណ្ឌលសុខភាពថ្មី និងមន្ទីរពេទ្យបង្អែកថ្មី** ត្រូវពិចារណាពីប្រសិទ្ធភាពប្រព័ន្ធសុខាភិបាល និងផលចំណេញសេដ្ឋកិច្ចដែលនឹងទទួលបានមកវិញ ពីការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងលើធនធានមនុស្ស ព្រមទាំងសក្តានុពលភាពនៃសេវាឯកជន។
4. **ជំរុញការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តមូលដ្ឋានដែលមានស្រាប់ តាមលទ្ធភាពថវិកា និងតាមវិធានការគន្លឹះក្នុងវិស័យសុខាភិបាល** ក្នុងការឆ្លើយតបនឹងមុខងារផ្តល់សេវាសុខាភិបាល និងតម្រូវការសុខភាពរបស់ប្រជាជន
5. **អភិវឌ្ឍជាបណ្តើរៗ មណ្ឌលសុខភាពមានគ្រែជាអតីតពេទ្យស្រុក ដែលមានលទ្ធភាព សក្តានុពលខ្ពស់ និងគ្របដណ្តប់ប្រជាជនសមស្រប ឱ្យទៅជាមន្ទីរពេទ្យបង្អែកកម្រិត១** ដើម្បីឆ្លើយតបនឹងគោលនយោបាយវិមជ្ឈការ និងកម្មវិធីអាទិភាពទី១ «ពង្រីកសេវាសុខភាពឆ្ពោះទៅកាន់ការគ្រប ដណ្តប់សុខភាពជាសកល»

# ២

# គោលដៅនៃផែនការ
# អភិវឌ្ឍន៍



ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល ឱ្យមានសង្គតិភាព ចីរភាព និងការប្រើប្រាស់ថវិកាមានប្រសិទ្ធភាពខ្ពស់ស្របនឹងអាទិភាពវិស័យសុខាភិបាល ផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានត្រូវបានរៀបចំមានគោលដៅ៖

១ តម្រង់ទិសធនធានឆ្ពោះទៅកាន់តំបន់ជនបទ ឬតំបន់ដែលមានសេវាសុខាភិបាលនៅមានកម្រិត ដើម្បីកាត់បន្ថយគម្លាតនៃការទទួលបានសេវាថែទាំសុខភាព និងលើកកម្ពស់សមធម៌សុខភាព

២ តម្រង់ទិសការវិនិយោគជាអាទិភាព ព្រមទាំងបញ្ជ្រាបផែនការនេះទៅក្នុងផែនការវិនិយោគនៅថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

៣ ជាមគ្គុទេសក៏សម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្នុងការដំឡើងកម្រិត ឬបង្កើតមូលដ្ឋានសុខាភិបាលថ្មី ឱ្យស្របតាមតម្រូវការសុខភាពជាក់ស្តែង ទំហំតម្រូវការសេវា មានប្រសិទ្ធភាពចំណាយខ្ពស់ ក្នុងបរិបទធនធានមានកម្រិត និងមានចីរភាព។

# ៣

# ផែនការសកម្មភាព



## ៣.១- វិសាលភាពនៃផែនការអភិវឌ្ឍន៍

ផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ២០២៦-២០៣០ បង្កើតឡើងសម្រាប់គាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាល (ប្រអប់២៖ គោលដៅយុទ្ធសាស្ត្រសុខាភិបាល) ឱ្យទទួលបានជោគជ័យ ដើម្បីសម្រេចចក្ខុវិស័យសុខភាព «**ប្រជាពលរដ្ឋគ្រប់រូបរស់នៅប្រកបដោយសុខភាព និងសុខុមាលភាព ដើម្បីចូលរួមក្នុងការអភិវឌ្ឍ មូលធនមនុស្ស និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព**» ក្នុងការរួមចំណែកសម្រេចយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ កម្មវិធីអាទិភាពទី១ «**ការពង្រឹកសេវាថែទាំសុខភាពឆ្ពោះទៅកាន់ការគ្របដណ្តប់សុខភាពជាសកល**» និងវិធានការគន្លឹះក្នុងវិស័យសុខាភិបាល (ប្រអប់៣ គោលដៅវិធានការគន្លឹះសុខាភិបាល)។ ផែនការអភិវឌ្ឍន៍បានផ្តោតលើ ការពង្រឹង ការពង្រីកប្រកបដោយចីរភាព និងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធចម្បងៗ ដើម្បីធានាដល់ដំណើរការផ្តល់សេវាសុខភាពបានពេញលេញ មានគុណភាព ចីរភាព និងបរិយាបន្ន ជាពិសេស នៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល។ វិសាលភាពនៃផែនការនេះ គ្របដណ្តប់លើការសាងសង់ថ្មី ការជួសជុល និងការកែលម្អពង្រីកហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់។

### ប្រអប់២៖ គោលដៅយុទ្ធសាស្ត្រសុខាភិបាល ២០២៥-២០៣៤

១ ប្រជាជនគ្រប់រូបទទួលបានការថែទាំសុខភាពពេញលេញ រួមទាំងការថែទាំសុខភាពបឋមមានគុណភាព នៅមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន ដែលជាគ្រឹះរឹងមាំសម្រាប់ការគ្របដណ្តប់សុខភាពជាសកល និងប្រព័ន្ធសុខាភិបាលមានភាពធន់

២ ធានាសេវាថែទាំសុខភាពដែលបានផ្តល់ដោយមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន មានអនុលោមភាពស្របតាមស្តង់ដាគ្លីនិក និងបង្កើនភាពពេញចិត្តរបស់អ្នកជំងឺ/អតិថិជន

៣ ប្រជាជនគ្រប់រូបទទួលបានសេវាថែទាំសុខភាពមានគុណភាព និងទាន់ពេល នៅពេលត្រូវការដោយមិនប្រឈមការលំបាកផ្នែកហិរញ្ញវត្ថុ

៤ ធានាប្រព័ន្ធសុខាភិបាលមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការត្រៀម ការសម្រប ការឆ្លើយតបនិងការស្តារស្ថានភាពឡើងវិញ ប្រកបដោយប្រសិទ្ធភាព ពីគ្រប់ទម្រង់នៃគ្រោះអាសន្នសុខភាព និងគ្រោះថ្នាក់សុខភាព។

### ប្រអប់៣៖ គោលដៅវិធានការគន្លឹះក្នុងវិស័យសុខាភិបាល

- គោលដៅទី១៖ គុណភាពសេវានៅមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ កម្រិត២ និងកម្រិត៣ ត្រូវបានកែលម្អឱ្យប្រសើរឡើងជាលំដាប់ ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុករបស់ប្រជាជន
- គោលដៅទី២៖ ប្រជាជនទទួលបានសេវាសង្គ្រោះបឋម និងសង្គ្រោះបន្ទាន់ត្រឹមត្រូវ និងទាន់ពេលវេលា ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដល់អាយុជីវិត
- គោលដៅទី៣៖ ប្រជាជនទទួលបានសេវាជំងឺឡើងសម្ពាធឈាម និងសេវាជំងឺទឹកនោមផ្អែម ក្នុងនោះមានសេវាបង្ការជំណាក់កាលបឋម
- គោលដៅទី៤៖ មណ្ឌលសុខភាពផ្តល់សេវា ២៤ម៉ោង/២៤ម៉ោង ៧ថ្ងៃ ក្នុង ១សប្តាហ៍ ដោយមានបុគ្គលិកតាមជំនាញបានពង្រាយ និងរក្សាទុក ស្របតាមនិយាមស្តង់ដារបុគ្គលិក ផ្អែកតាមកត្តាភូមិសាស្ត្រ និងចំនួនប្រជាជនគ្របដណ្តប់

ផែនការនេះក៏ផ្តោតលើការធានាដល់ការពង្រាយហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឱ្យមានភាពសមស្របតាមភូមិសាស្ត្រ តាមតម្រូវការសុខភាពពិតប្រាកដរបស់ប្រជាពលរដ្ឋ និន្នាការកំណើនប្រជាជន និងបន្ទុកសេវា។ លើសពីនេះ ផែនការបានបញ្ចូលគម្រោងកែលម្អប្រព័ន្ធគាំទ្រចាំបាច់ ដូចជា បណ្តាញទឹកស្អាត អនាម័យ បណ្តាញអគ្គិសនី និងការគ្រប់គ្រងសំណល់ ដើម្បីធានាឱ្យមូលដ្ឋានសុខាភិបាលអាចដំណើរការបានប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងស្របតាមស្តង់ដារជាតិ។

ជាមួយគ្នាដែរ ផែនការអភិវឌ្ឍន៍ក៏បានគិតគូលើការថែទាំ ការជួសជុលជាប្រចាំប្រកបដោយចីរភាពសម្រាប់រយៈពេលវែង ព្រមទាំងការពង្រឹងយន្តការគ្រប់គ្រង ការសម្របសម្រួលរវាងក្រសួង អាជ្ញាធរថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ ដើម្បីធានាឱ្យការអនុវត្តផែនការនេះប្រព្រឹត្តទៅដោយមានប្រសិទ្ធភាពខ្ពស់ និងទទួលបានលទ្ធផលល្អប្រសើរ ក្នុងអំឡុងពេល ៥ឆ្នាំ ២០២៦–២០៣០។

## ៣.២- ការព្យាករណ៍ និងប៉ាន់ស្មានចំនួនមូលដ្ឋានសុខាភិបាលឆ្នាំ២០២៦-២០៣០ ក្នុងវិស័យសុខាភិបាល

ក្នុងឆ្នាំ២០២៥ កម្ពុជាមាន រាជធានីមួយ និងខេត្តចំនួន ២៤ ចែកចេញជា ៣៣ ក្រុង ១៤ ខណ្ឌ ១៦៣ ស្រុក ២៧៤ សង្កាត់ ១ ៣៧៨ ឃុំ និង ១៤ ៥៧៨ ភូមិ។ រចនាសម្ព័ន្ធរដ្ឋបាលទាំងអស់ត្រូវបានគ្រប់គ្រងតាមច្បាប់អង្គការ។ ក្នុងឆ្នាំ២០២៥ កម្ពុជាមានប្រជាជនចំនួន ១៧ ៥៧៧ ៧៦០នាក់ (អត្រាកំណើន

ប្រចាំឆ្នាំ ១,៤% ក្នុងឆ្នាំ២០២៥)។ សមាមាត្រប្រជាជនរស់នៅតំបន់ទីក្រុងបានកើនទ្វេដង ពី២០% នៅឆ្នាំ២០០៨ ដល់ ៤១,៥% នៅឆ្នាំ២០២៤។ តាមការព្យាករណ៍ ប្រជាជនកម្ពុជានឹងកើនដល់ ២២ លាននាក់ នៅដំណាច់ឆ្នាំ២០៥០ (ឆ្នាំ២០៣០ ប៉ាន់ប្រមាណចំនួន ១៨ ៧៣៥ ៩៧៧នាក់) ហើយរចនាសម្ព័ន្ធ អាយុក៏នឹងផ្លាស់ប្តូរទៅតាមនោះដែរ ក្នុងនោះប្រជាជនអាយុលើសពី ៦០ឆ្នាំ នឹងកើនលើសពី ២៣% នៃប្រជាជនសរុប (ក្រាហ្វិច ១ បង្ហាញពីនិន្នាការនៃការប៉ាន់ស្មានចំនួនប្រជាជន ពីឆ្នាំ២០២៥-២០៣០)។

**ក្រាហ្វិច ១៖ និន្នាការនៃការប៉ាន់ស្មានចំនួនប្រជាជនពីឆ្នាំ២០២៥-២០៣០**




ប្រភព៖ Populaton projection 2020-2033, National Institution of Statistics, Ministry of Planning

ផ្អែកតាមកំណើនចំនួនប្រជាជនប្រចាំឆ្នាំ លក្ខណៈវិនិច្ឆ័យនៃការបង្កើតមូលដ្ឋានសុខាភិបាល និង គោលនយោបាយវិមជ្ឈការ (ការតម្រៀបបណ្តើរៗតំបន់ទទួលខុសត្រូវរបស់ស្រុកប្រតិបត្តិ ជាមួយព្រំប្រទល់ស្រុករដ្ឋបាល និងតំបន់ទទួលខុសត្រូវរបស់មណ្ឌលសុខភាពជាមួយព្រំប្រទល់ឃុំ ឬសង្កាត់) ដោយគិតមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហាក់ប្រហែលបច្ចុប្បន្ន ចំនួន ១៣ ៤០០ នាក់ ព្រមទាំង គម្រោងផែនការគ្របដណ្តប់សុខាភិបាលដែលបានលើកឡើងដោយមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ការប៉ាន់ស្មានចំនួនមណ្ឌលសុខភាពបង្កើតថ្មី/ដំឡើងពីប៉ុស្តិ៍សុខភាព មានចំនួន ៩១ កន្លែង និងមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ១១ កន្លែង ក្នុងរយៈពេល៥ឆ្នាំ (ឆ្នាំ២០២៦-២០៣០)។ គិតជាមធ្យមក្នុងមួយឆ្នាំ មានមណ្ឌលសុខភាពបង្កើតថ្មី/ដំឡើងពីប៉ុស្តិ៍សុខភាព ចំនួន ១៨ កន្លែង និងមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ២ កន្លែង (តារាង ៤ បង្ហាញពីការព្យាករណ៍ចំនួនមូលដ្ឋានសុខាភិបាល (បង្កើត/ដំឡើងកម្រិត) ផ្អែកតាមកំណើនប្រជាជននិងភូមិសាស្ត្រ និងគម្រោងផែនការគ្របដណ្តប់សុខាភិបាលរបស់មន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានី ខេត្ត ពីឆ្នាំ២០២៦-២០៣០)។ ដោយឡែក ផែនការក្នុងឆ្នាំ២០២៦ ក្រសួងសុខាភិបាល

បានបញ្ចូលសំណើសុំបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាល របស់រដ្ឋបាលរាជធានី ខេត្ត ក្នុងឆ្នាំ២០២៤ ចំនួន ២០ កន្លែង ក្នុងឆ្នាំ២០២៥ ចំនួន ២៤ កន្លែង និងសំណើសុំដែលបានទទួលដោយនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល ក្នុងឆ្នាំ២០២៦។ ការណ៍នេះ បណ្តាលឱ្យចំនួនមូលដ្ឋានសុខាភិបាលដែលត្រូវបង្កើត/ដំឡើងកម្រិតក្នុងផែនការឆ្នាំ២០២៦ កើនច្រើនដល់ចំនួន ៦១កន្លែង។

**តារាង ៥៖ ការព្យាករណ៍ចំនួនមូលដ្ឋានសុខាភិបាល និងបុគ្គលិកជំនាញ (បង្កើត/ដំឡើងកម្រិត) ផ្អែកតាមកំណើនប្រជាជន និងភូមិសាស្ត្រ ពីឆ្នាំ២០២៦-២០៣០**

| បរិយាយ | ២០២៥* (បន្ទាត់មូលដ្ឋាន) | ២០២៦** | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 8 | 37 | 243 | 9 | 72 | 9 | 72 | 10 | 80 | 9 | 72 |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | 1 | 6 | 32 | 4 | 26 | 1 | 8 | 5 | 32 | 1 | 8 |
| ប៉ុស្តិ៍សុខភាពថ្មី | 9 | 9 | 26 | - | - | 1 | 2 | - | - | 1 | 2 |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | 1 | 1 | 45 | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | 1 | 5 | 129 | 3 | 90 | - | - | 2 | 60 | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ ដំឡើងពីកម្រិត១ | - | - | - | 3 | 90 | 5 | 150 | 3 | 90 | 4 | 120 |
| មន្ទីរពេទ្យបង្អែកកម្រិត៣ ដំឡើងពីកម្រិត២ | - | - | - | 1 | 30 | 1 | 30 | - | - | - | - |
| ស្រុកប្រតិបត្តិ | 1 | 3 | 41 | - | - | - | - | 1 | 20 | 1 | 20 |
| **សរុប** | **21** | **61** | **516** | **20** | **308** | **17** | **262** | **21** | **282** | **16** | **222** |

**សម្គាល់៖**

* ប្រកាសអន្តរក្រសួងលេខ ០០៧៥ ស.នក.ប្រកអ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៥ ស្តីពី ការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាល

** សំណើរបស់រដ្ឋបាលខេត្តក្នុងឆ្នាំ២០២៤ និងឆ្នាំ២០២៥ ត្រូវបានបញ្ចូលជាផែនការឆ្នាំ២០២៦ (បានស្នើទៅក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួចហើយ)។

សំណើសុំបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលរបស់រាជធានី ខេត្ត រួមមាន៖

- ឆ្នាំ២០២៤ រដ្ឋបាលខេត្តចំនួន ៩ បានស្នើសុំបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ២០កន្លែង ក្នុងនោះ បង្កើតមណ្ឌលសុខភាពថ្មីចំនួន ៩កន្លែង ដំឡើងពីប៉ុស្តិ៍សុខភាពទៅជាមណ្ឌលសុខភាពចំនួន ៣កន្លែង បង្កើតប៉ុស្តិ៍សុខភាពថ្មី ៣កន្លែង បង្កើតមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ១កន្លែង ដំឡើងពីមណ្ឌលសុខភាពទៅជាមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ២កន្លែង និងបង្កើតការិយាល័យសុខាភិបាលស្រុកប្រតិបត្តិថ្មីចំនួន ២កន្លែង។
- ឆ្នាំ២០២៥ រដ្ឋបាលខេត្តចំនួន ៩ បានស្នើសុំបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ២៤កន្លែង ក្នុងនោះ បង្កើតមណ្ឌលសុខភាពថ្មីចំនួន ១៥កន្លែង ដំឡើងពីប៉ុស្តិ៍សុខភាពទៅជាមណ្ឌលសុខភាពចំនួន ២កន្លែង បង្កើតប៉ុស្តិ៍សុខភាពថ្មី ៥កន្លែង មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាពចំនួន ១កន្លែង និងបង្កើតការិយាល័យសុខាភិបាលស្រុកប្រតិបត្តិថ្មីចំនួន ១កន្លែង។
- ឆ្នាំ២០២៦ នាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាលបានទទួលសំណើពីរដ្ឋបាលរាជធានី ខេត្តចំនួន ៧ ក្នុងនោះ ស្នើបង្កើតមណ្ឌលសុខភាពចំនួន ៦កន្លែង ដំឡើងពីប៉ុស្តិ៍សុខភាពទៅជាមណ្ឌលសុខភាពចំនួន ១កន្លែង បង្កើតប៉ុស្តិ៍សុខភាព ១កន្លែង និងដំឡើងពីមណ្ឌលសុខភាពទៅជាមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ២កន្លែង។

## ៣.៣- ការព្យាករណ៍ និងប៉ាន់ស្មានចំនួនមូលដ្ឋានសុខាភិបាលតាមរាជធានី ខេត្ត ពីឆ្នាំ ២០២៦-២០៣០

តាមផែនការរយៈពេល៥ឆ្នាំ ដែលបានលើកដោយមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ដែលបានគ្រោងបង្កើតមណ្ឌលសុខភាពថ្មី ចំនួន ១៣៦កន្លែង មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព ៤០ កន្លែង ប៉ុស្តិ៍សុខភាពថ្មី ១៧កន្លែង មន្ទីរពេទ្យកម្រិត១ ចំនួន ១៣ កន្លែង មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព ២០កន្លែង មន្ទីរពេទ្យបង្អែកកម្រិត២ ដំឡើងពីកម្រិត១ ចំនួន ១៩កន្លែង មន្ទីរពេទ្យបង្អែកកម្រិត៣ ដំឡើងពីកម្រិត២ ចំនួន ២កន្លែង(មន្ទីរពេទ្យបង្អែកខេត្តកោះកុង និងខេត្តមណ្ឌលគិរី) និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ៧កន្លែង ព្រមទាំងតម្រូវការបុគ្គលិកក្នុងរយៈពេល៥ឆ្នាំ ចំនួន ៣ ៥១២នាក់។

យោងសនិទានកម្មនៃមូលដ្ឋានសុខាភិបាលបច្ចុប្បន្ន រាជធានីភ្នំពេញ និងទីរួមខេត្ត ការបង្កើតមូលដ្ឋានសុខាភិបាលថ្មី មិនមែនជាតម្រូវការចាំបាច់ ដោយសារប្រជាជនប្រមូលផ្តុំ ផ្លូវគមនាគមន៍ងាយស្រួល និងមូលដ្ឋានសុខាភិបាលឯកជនមានច្រើន ដែលអាចឱ្យប្រជាជនទៅទទួលយកសេវាបានងាយស្រួល។ ផ្ទុយទៅវិញ ចំពោះតំបន់ជនបទ និងតំបន់ដាច់ស្រយាល គឺជាអាទិភាពក្នុងការពង្រាយមូលដ្ឋានសុខាភិបាល

ឱ្យសមស្របទៅតាមតម្រូវការ និងមានភាពងាយស្រួលក្នុងការមកទទួលសេវារបស់ប្រជាជន។ ខេត្តមួយចំនួនដែលមានប្រជាជនតិច និងតំបន់គ្របដណ្តប់តូច មិនគួរឱ្យបង្កើតបន្ថែមមូលដ្ឋានសុខាភិបាលលើសពីបច្ចុប្បន្នឡើយ។

ការព្យាករណ៍ និងប៉ាន់ស្មានចំនួនមូលដ្ឋានសុខាភិបាលតាមរាជធានី ខេត្ត ពីឆ្នាំ២០២៦-២០៣០ តាមរយៈការវិភាគពី កំណើនប្រជាជនតាមខេត្ត ទីតាំងភូមិសាស្ត្រ ការតម្រៀបតម្រឹមតំបន់គ្របដណ្តប់តាមព្រំដែនរដ្ឋបាល និងផែនការគ្របដណ្តប់សុខាភិបាលដែលបានលើកឡើងដោយមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ដែលមានបង្ហាញក្នុងតារាង ៦។

**តារាង ៦៖ ការព្យាករណ៍ចំនួនមូលដ្ឋានសុខាភិបាលតាមរាជធានី ខេត្ត រវាងឆ្នាំ២០២៦-២០៣០**

| រាជធានី ខេត្ត | ឆ្នាំ២០២៦-២០៣០ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | មណ្ឌលសុខភាពថ្មី | មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | ប៉ុស្តិ៍សុខភាពថ្មី | មន្ទីរពេទ្យបង្អែកកម្រិត១ថ្មី | មន្ទីរពេទ្យបង្អែកកម្រិត១ដំឡើងពីមណ្ឌលសុខភាព | មន្ទីរពេទ្យបង្អែកកម្រិត២ដំឡើងពីកម្រិត១ | មន្ទីរពេទ្យបង្អែកកម្រិត៣ដំឡើងពីកម្រិត២ | ស្រុកប្រតិបត្តិ |
| បន្ទាយមានជ័យ | 1 | 4 | - | - | - | 1 | - | - |
| បាត់ដំបង | 6 | 1 | 1 | - | 2 | - | - | - |
| កំពង់ចាម | 5 | - | 1 | - | - | 1 | - | - |
| កំពង់ឆ្នាំង | 5 | - | 2 | - | - | 1 | - | 1 |
| កំពង់ស្ពឺ | 2 | - | - | - | - | - | - | 1 |
| កំពង់ធំ | 5 | - | - | - | 2 | - | - | - |
| កំពត | 5 | - | - | - | 1 | - | - | - |
| កណ្តាល | 6 | - | 3 | - | - | 1 | - | 1 |
| កោះកុង | - | 1 | - | - | - | 1 | 1 | - |
| ក្រចេះ | 2 | 1 | | | | | | |
| មណ្ឌលគិរី | - | 2 | - | - | - | - | 1 | - |
| រាជធានីភ្នំពេញ | - | - | - | - | - | 1 | - | - |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ព្រះវិហារ | 2 | 1 | - | - | 1 | 1 | - | 1 |
| ព្រៃវែង | 4 | 1 | - | - | - | 2 | - | - |
| ពោធិ៍សាត់ | 5 | - | - | - | - | 1 | - | - |
| រតនគិរី | - | 3 | - | - | - | - | - | - |
| សៀមរាប | 4 | - | - | 1 | - | 1 | - | - |
| ព្រះសីហនុ | 3 | - | - | - | 2 | - | - | - |
| ស្ទឹងត្រែង | 3 | 2 | 3 | - | 1 | - | - | - |
| ស្វាយរៀង | 5 | - | 1 | - | - | 1 | - | - |
| តាកែវ | 6 | - | - | - | - | 1 | - | 1 |
| ឧត្តរមានជ័យ | 3 | 1 | - | - | - | 1 | - | - |
| ប៉ៃលិន | 1 | - | - | - | - | - | - | - |
| កែប | - | - | - | - | - | - | - | - |
| ត្បូងឃ្មុំ | 1 | - | - | - | - | 1 | - | - |
| **សរុបរួម** | **74** | **17** | **11** | **1** | **10** | **15** | **2** | **5** |

ការព្យាករណ៍ផែនការ អំពីចំនួនមូលដ្ឋានសុខាភិបាលតាមរាជធានី ខេត្តនីមួយៗ ត្រូវបានវិភាគលម្អិតក្នុងក្របខណ្ឌជាក់លាក់នៃស្ថានភាពរបស់រាជធានី ខេត្ត ដូចខាងក្រោម៖

## ១ ខេត្តបន្ទាយមានជ័យ

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តបន្ទាយមានជ័យ មានក្រុងចំនួន ២ ស្រុកចំនួន ៧ ឃុំ/សង្កាត់ចំនួន ៦៧ ភូមិចំនួន ៦៦៦ និងប្រជាជនចំនួន ៩៧៤ ៩៣៤នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន៦ មន្ទីរពេទ្យបង្អែកចំនួន ៩ មណ្ឌលសុខភាពចំនួន ៦៩ និងប៉ុស្តិ៍សុខភាព១៤។ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការ កំណើនប្រជាជននៅឆ្នាំ២០៣០ មានចំនួន ១ ០៣៨ ២៦៧ នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ១៤ ០៣០ នាក់ ខេត្តបន្ទាយមានជ័យ មានមណ្ឌលសុខភាពដែលគួរបង្កើតថ្មី មានចំនួន ៥ កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តបន្ទាយមានជ័យ ការបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៦ កន្លែង ក្នុងនោះ មណ្ឌលសុខភាពថ្មី ១ កន្លែង ដំឡើងកម្រិត ពីប៉ុស្តិ៍សុខភាពទៅមណ្ឌលសុខភាពមានចំនួន ៤ កន្លែង និងដំឡើងមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១ កន្លែង ព្រមទាំងតម្រូវការបុគ្គលិកបន្ថែមចំនួន ៥៩ នាក់ (តារាង ៧)។

**តារាង ៧៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តបន្ទាយមានជ័យ ពីឆ្នាំ ២០២៦-២០៣០**

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 1 | 8 | - | - | - | - | - | - | - | - |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | - | - | 1 | +8 | 1 | +8 | 1 | +8 | 1 | +8 |
| ប៉ុស្តិ៍សុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | - | - | - | - | 1 | +20 |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋាន៖**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តបន្ទាយមានជ័យ មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៦ កន្លែង ក្នុងនោះ បង្កើតមណ្ឌលសុខភាពថ្មី ១ កន្លែង ដំឡើងកម្រិតពីប៉ុស្តិ៍សុខភាពទៅជាមណ្ឌលសុខភាពចំនួន ៤ កន្លែង និងដំឡើងមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១ កន្លែង (ឧបសម្ព័ន្ធ ១)។

រីឯ ការជួសជុលអគារមូលដ្ឋានសុខាភិបាល មានចំនួន ១១០ អគារ និងសាងសង់ថ្មី/ពង្រីក ចំនួន ៨៥ អគារ ដោយគ្រោងថវិកាជាតិ ១៨ ៤៧៣ លានរៀល (ឧបសម្ព័ន្ធ ២)។

## ២ ខេត្តបាត់ដំបង

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តបាត់ដំបង មានក្រុងចំនួន ១ ស្រុកចំនួន ១៣ ឃុំ/សង្កាត់ចំនួន ១០៣ ភូមិចំនួន ៨៤៤ និងប្រជាជនចំនួន ១ ១២៧ ០៤២នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ៥ និងមានមន្ទីរពេទ្យបង្អែកចំនួន ៩ មណ្ឌលសុខភាពចំនួន ៨២ និងប៉ុស្តិ៍សុខភាព១។ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការ កំណើនប្រជាជនដល់ឆ្នាំ២០៣០ មានចំនួន ១ ២០១ ២៤០នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ១៣ ៨០៧នាក់ ខេត្តបាត់ដំបង មានមណ្ឌលសុខភាពដែលគួរបង្កើតថ្មី មានចំនួន ៧ កន្លែង។

តាមផែនការមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តបាត់ដំបង គ្រោងបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ២០ កន្លែង ក្នុងនោះ បង្កើតមណ្ឌលសុខភាពថ្មី ១៣ កន្លែង ដំឡើងកម្រិតពីប៉ុស្តិ៍សុខភាពទៅមណ្ឌលសុខភាព ១ កន្លែង និងដំឡើងមណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ៦ កន្លែង (តារាង ៨) និងតម្រូវការបុគ្គលិកបន្ថែមចំនួន ២៥៨នាក់។

**តារាង ៨៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តបាត់ដំបង ពីឆ្នាំ២០២៦-២០៣០**

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 3 | +17 | 2 | +16 | 3 | +24 | 3 | +24 | 2 | +16 |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | - | - | 1 | +5 | - | - | - | - | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | | | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពី មណ្ឌលសុខភាព | 2 | +44 | - | - | 1 | +29 | - | - | 3 | +80 |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋានៈ**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តបាត់ដំបង មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ១០កន្លែង ក្នុងនោះ បង្កើតមណ្ឌលសុខភាពថ្មី ៦កន្លែង ដំឡើងកម្រិតពីប៉ុស្តិ៍សុខភាពទៅមណ្ឌលសុខភាពមានចំនួន ១ កន្លែង ប៉ុស្តិ៍សុខភាពថ្មី ១កន្លែង និងដំឡើងមណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ២កន្លែង (ឧបសម្ព័ន្ធ ១)។

ការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ៣៨កន្លែង និងសាងសង់ថ្មី/ពង្រីកចំនួន ៣១កន្លែង ដែលត្រូវការថវិកាជាតិចំនួន ៨៨ ៦៤១លានរៀល (ឧបសម្ព័ន្ធ២)។

## ៣ ខេត្តកំពង់ចាម

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តកំពង់ចាម មានក្រុងចំនួន១ ស្រុកចំនួន ៩ ឃុំ/សង្កាត់ចំនួន ១០៩ ភូមិចំនួន ៩៤៧ និងប្រជាជនចំនួន ១ ០១៦ ៩៨១នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ៩ មន្ទីរពេទ្យបង្អែកចំនួន ៩ មណ្ឌលសុខភាពចំនួន ៩៦ និងប៉ុស្តិ៍សុខភាព ៤។ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការ នៅឆ្នាំ២០៣០ ប្រជាជនក្នុងខេត្តកំពង់ចាម កើនដល់ ១ ០៨៣ ៩៣៤នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ១០ ៧៣២នាក់ ខេត្តកំពង់ចាម មានមណ្ឌលសុខភាពដែលគួរបង្កើតថ្មី ចំនួន ៥ កន្លែង។

តាមផែនការមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ចាម គ្រោងបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ១០ កន្លែង ក្នុងនោះ មណ្ឌលសុខភាពបង្កើតថ្មី ៩ កន្លែង ដំឡើងកម្រិតទៅជាមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១កន្លែង (តារាង ៩) និងតម្រូវការបុគ្គលិកបន្ថែមចំនួន ៥០នាក់។

**តារាង ៩៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តកំពង់ចាម ពីឆ្នាំ២០២៦-២០៣០**

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 4 | + 20 | 3 | +8 | 2 | +8 | - | - | - | - |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | - | - | - | - | - | - | - | - | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | - | - | - | - | - | - | - | - | - | - |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | 1 | +20 | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋាន៖**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ចាម មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៧ កន្លែង ក្នុងនោះ មណ្ឌលសុខភាពថ្មី ៥កន្លែង ប៉ុស្តិ៍សុខភាពថ្មី ១កន្លែង និងដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១ កន្លែង (ឧបសម្ព័ន្ធ ១)។

រីឯការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ២អគារ និងសាងសង់ថ្មី/ពង្រីកចំនួន ២៥ អគារ ដែលគ្រោងប្រើប្រាស់ថវិកាជាតិ ១២ ១៨០លានរៀល និងអង្គការដៃគូរអភិវឌ្ឍដូចជា ADB និងអង្គការ Jica (ឧបសម្ព័ន្ធ២)។

## ៤ ខេត្តកំពង់ឆ្នាំង

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តកំពង់ឆ្នាំង មានក្រុងចំនួន ១ ស្រុកចំនួន ៧ ឃុំ/សង្កាត់ចំនួន ៧១ ភូមិចំនួន ៥៦៩ និងប្រជាជនចំនួន ៥៩៥ ៦៦៨នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ៣ និងមានមន្ទីរពេទ្យបង្អែកចំនួន ៣ មណ្ឌលសុខភាពចំនួន ៤៥ និងប៉ុស្តិ៍សុខភាព១។ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការកំណើនប្រជាជនឆ្នាំ២០៣០ ចំនួន៦៣៤ ៨៨៤នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ១២ ៩៥៦នាក់ ខេត្តកំពង់ឆ្នាំង មានមណ្ឌលសុខភាពដែលត្រូវបង្កើតថ្មីចំនួន ៥កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ឆ្នាំង គ្រោងបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ១៤ កន្លែង ក្នុងនោះ មណ្ឌលសុខភាព ១០កន្លែង ប៉ុស្តិ៍សុខភាព ២កន្លែង ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ១កន្លែង ដំឡើងកម្រិតពីមន្ទីរពេទ្យកម្រិត១ទៅកម្រិត២ ១កន្លែង (តារាង ១០) និងតម្រូវការបុគ្គលិកបន្ថែមចំនួន៣៨នាក់។

### តារាង១០៖គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តកំពង់ឆ្នាំងពីឆ្នាំ២០២៦-២០៣០

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 2 | +8 | 2 | +16 | 2 | +16 | 2 | +16 | 2 | +16 |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | - | - | - | - | - | - | - | - | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | 2 | +4 | | | | | | | | |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | 1 | +18 | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | 1 | +8 | - | - | - | - | - | - | - | - |

**ការសន្និដ្ឋាន៖**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ឆ្នាំង មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាល សរុបចំនួន ៩ កន្លែង ក្នុងនោះ មណ្ឌលសុខភាពថ្មី ៥ កន្លែង ប៉ុស្តិ៍សុខភាព ២កន្លែង ដំឡើងកម្រិតពីមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១កន្លែង និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ចំនួន ១ កន្លែង (ឧបសម្ព័ន្ធ ១)។

រីឯការជួសជុលអគារមូលដ្ឋានសុខាភិបាលមានចំនួន ១៨ អគារ ដែលគ្រោងប្រើប្រាស់ថវិការបស់អង្គភាព និងសាងសង់ថ្មី/ពង្រីកចំនួន ៤ អគារ ប្រើប្រាស់ថវិកាជាតិ (ឧបសម្ព័ន្ធ២) ។

## ៥ ខេត្តកំពង់ស្ពឺ

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តកំពង់ស្ពឺ មានក្រុងចំនួន ២ ស្រុកចំនួន៧ ឃុំ/សង្កាត់ចំនួន៨៨ ភូមិចំនួន ១៣៦៥ និងប្រជាជនចំនួន ៩៩១ ៨១៣នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ៤ និង មានមន្ទីរពេទ្យបង្អែកចំនួន ៤ មណ្ឌលសុខភាពចំនួន ៦២ និងប៉ុស្តិ៍សុខភាព ៣។ ផ្អែកតាមការព្យាករណ៍ របស់ក្រសួងផែនការកំណើនប្រជាជនឆ្នាំ២០៣០ ចំនួន ១ ០៥៧ ១០៨នាក់ និងតាមមណ្ឌលសុខភាព១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ១៥ ៣២០នាក់ ខេត្តកំពង់ស្ពឺមានមណ្ឌលសុខភាពដែលត្រូវបង្កើតថ្មី នៅត្រឹមឆ្នាំ២០៣០ មានចំនួន ៥ កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ស្ពឺ គ្រោងបង្កើតនិងដំឡើងកម្រិតមូលដ្ឋាន សុខាភិបាលសរុបចំនួន ៣កន្លែង៖ មណ្ឌលសុខភាព ២កន្លែង ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ១កន្លែង (តារាង ១១) និងតម្រូវការបុគ្គលិកបន្ថែមចំនួន២៥នាក់។

### តារាង១១៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តកំពង់ស្ពឺ ពីឆ្នាំ២០២៦-២០៣០

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 2 | 10 | - | - | - | - | - | - | - | - |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | - | - | - | - | - | - | - | - | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | 1 | 15 | - | - | - | - | - | - | - | - |

**ការសន្និដ្ឋាន៖**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ស្ពឺ មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៣កន្លែង ក្នុងនោះ បង្កើតមណ្ឌលសុខភាពថ្មី ២កន្លែង និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំនួន ១កន្លែង (ឧបសម្ព័ន្ធ ១)។

រីឯការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ១៤អគារ និងសាងសង់ថ្មី/ពង្រីកចំនួន ៦អគារ ដោយគ្រោងប្រើប្រាស់ថវិការជាតិ ៧ ១៩៦ លានរៀល (ឧបសម្ព័ន្ធ ២) ។

## ៦ ខេត្តកំពង់ធំ

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តកំពង់ធំ មានក្រុងចំនួន ១ ស្រុកចំនួន ៨ ឃុំ/សង្កាត់ចំនួន ៨១ ភូមិចំនួន ៧៦៥ និងប្រជាជនចំនួន ៧៧០ ៣១៥នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ៣ មន្ទីរពេទ្យបង្អែកចំនួន៣ មណ្ឌលសុខភាពចំនួន៥៦ និងប៉ុស្តិ៍សុខភាព៥។ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការ កំណើនប្រជាជននឆ្នាំ២០៣០ ចំនួន ៨២១ ០២៩នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ១៣ ៤៥៩នាក់ ខេត្តកំពង់ធំមានមណ្ឌលសុខភាពដែលគួរបង្កើតថ្មីនៅត្រឹមឆ្នាំ២០៣០ មានចំនួន ៥ កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ធំ គ្រោងបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ១៤ កន្លែង៖ មណ្ឌលសុខភាព ១២ កន្លែង ដំឡើងកម្រិតពីមណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ២ កន្លែង (តារាង ១២) និងតម្រូវការបុគ្គលិកបន្ថែមចំនួន ១០៦នាក់។

**តារាង១២៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តកំពង់ធំ ពីឆ្នាំ២០២៦-២០៣០**

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 2 | +16 | 4 | +32 | 2 | +16 | 2 | +16 | 2 | +16 |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | - | - | - | - | - | - | - | - | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | 1 | +5 | - | - | 1 | +5 | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋាន៖**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ធំ មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៧ កន្លែង ក្នុងនោះ មណ្ឌលសុខភាពថ្មី ៥ កន្លែង ដំឡើងកម្រិតពីមណ្ឌលសុខភាព ទៅមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ២កន្លែង (ឧបសម្ព័ន្ធ ១)។

រីឯការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន១៣អគារ និងសាងសង់ថ្មី/ពង្រីកចំនួន១៤អគារ ដោយគ្រោងប្រើថវិកាជាតិ ៩ ៣៤៥ លានរៀល (ឧបសម្ព័ន្ធ ២)។

## ៧ ខេត្តកំពត

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តកំពត មានក្រុងចំនួន ២ ស្រុកចំនួន ៧ ឃុំ/សង្កាត់ចំនួន ៩៣ ភូមិចំនួន ៤៩១ និងប្រជាជនចំនួន ៦៧១ ១៧០នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ៤ និងមានមន្ទីរពេទ្យបង្អែកចំនួន ៥ មណ្ឌលសុខភាពចំនួន ៦៦ និងប៉ុស្តិ៍សុខភាព១។ ផ្អែកតាមកំណើនប្រជាជននៃការព្យាករណ៍របស់ក្រសួងផែនការនៃឆ្នាំ២០៣០ ចំនួន ៧១៥ ៥០៣ នាក់ និងតាមមណ្ឌលសុខភាពមួយបម្រើប្រជាជនចំនួន ១០ ៦៧៩នាក់ ខេត្តកំពតមានមណ្ឌលសុខភាពដែលត្រូវបង្កើតថ្មីមានចំនួន ៥កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពត គ្រោងបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៩កន្លែង ក្នុងនោះ បង្កើតមណ្ឌលសុខភាព ៨កន្លែង ដំឡើងកម្រិតពីមណ្ឌលសុខភាពទៅជាមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន១កន្លែង (តារាង ១៣) និងតម្រូវការបន្ថែមបុគ្គលិកចំនួន៩៤នាក់។

### តារាង១៣៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តកំពត ពីឆ្នាំ២០២៦-២០៣០

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | - | - | - | - | 2 | +16 | - | - | 6 | +48 |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | - | - | - | - | - | - | - | - | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | 1 | +30 | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋាន៖**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពត មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៦កន្លែង ក្នុងនោះ មណ្ឌលសុខភាពថ្មី ៥កន្លែង ដំឡើងកម្រិតពីមណ្ឌលសុខភាព ទៅមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ១កន្លែង (ឧបសម្ព័ន្ធ ១)។

រីឯការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ៤៧អគារ និងសាងសង់ថ្មី/ពង្រីកចំនួន ៣៨អគារ ដែលគ្រោងប្រើប្រាស់ថវិការជាតិ ៧ ៨១៩ លានរៀល (ឧបសម្ព័ន្ធ ២) ។

## ៨ ខេត្តកណ្ដាល

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តកណ្ដាល មានក្រុងចំនួន ៣ ស្រុកចំនួន ១០ ឃុំ/សង្កាត់ចំនួន ១២៧ភូមិចំនួន ១០១០ និងប្រជាជនចំនួន ១ ៣៥៨ ០៧៧នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ១០ និងមានមន្ទីរពេទ្យបង្អែកចំនួន ១១ មណ្ឌលសុខភាពចំនួន ១០៧ និងប៉ុស្តិ៍សុខភាព៣។ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការកំណើនប្រជាជនឆ្នាំ២០៣០ ចំនួន ១ ៤៤៧ ៤៨៥នាក់ និងតាមមណ្ឌលសុខភាព១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ១២ ៦៩៧ នាក់ ខេត្តកណ្ដាលមានមណ្ឌលសុខភាពដែលគួរបង្កើតថ្មីមានចំនួន ៧ កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកណ្ដាល គ្រោងបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ២៧ កន្លែង ក្នុងនោះ បង្កើតមណ្ឌលសុខភាព ២០កន្លែង ដំឡើងកម្រិតប៉ុស្តិ៍សុខភាពទៅជាមណ្ឌលសុខភាព ៣កន្លែង ដំឡើងកម្រិតមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១ កន្លែង (តារាង ១៤) និងតម្រូវការបន្ថែមបុគ្គលិកចំនួន ២៣៥នាក់។

**តារាង ១៤៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តកណ្ដាល ពីឆ្នាំ២០២៦-២០៣០**

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 2 | 13 | 2 | +16 | 2 | +16 | 6 | +48 | 4 | +32 |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | - | - | - | - | 1 | +8 | 1 | +8 | 1 | +8 |
| ប៉ុស្តិ៍សុខភាពថ្មី | 3 | 12 | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | 1 | +20 | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | 1 | 18 | 2 | +36 | - | - | - | - | - | - |

**ការសន្និដ្ឋានៈ**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកណ្ដាល គួរបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ១១ កន្លែង ក្នុងនោះ មណ្ឌលសុខភាពថ្មី ៦ កន្លែង ប៉ុស្តិ៍សុខភាព ៣កន្លែង និងដំឡើងកម្រិតមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១កន្លែង និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំនួន ១កន្លែង( ឧបសម្ព័ន្ធ ១ )។

រីឯការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ១៥អគារ និងសាងសង់ថ្មី/ពង្រីកចំនួន ២១កន្លែង ដែលគ្រោងប្រើប្រាស់ថវិកា ១៦ ៨៨៤ លានរៀល ( ឧបសម្ព័ន្ធ ២ ) ។

## ៩ ខេត្តកោះកុង

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តកោះកុង មានក្រុងចំនួន ១ ស្រុកចំនួន ៦ ឃុំ/សង្កាត់ចំនួន ២៩ ភូមិចំនួន ១១៩ និងប្រជាជនចំនួន ១៤២ ៣០០នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ២ មន្ទីរពេទ្យបង្អែកចំនួន ២ មណ្ឌលសុខភាពចំនួន ១៥ និងប៉ុស្តិ៍សុខភាព១១។ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការ កំណើនប្រជាជននៅឆ្នាំ២០៣០ មានចំនួន ១៥១ ៦៦៨ នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ១០ ១១១ នាក់ ខេត្តកោះកុង មិនគួរបង្កើតថ្មីទេ ប៉ុន្តែអាចពិនិត្យលទ្ធភាពនៃការដំឡើងពីប៉ុស្តិ៍សុខភាពទៅជាមណ្ឌលសុខភាព។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកោះកុង ការបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៤ កន្លែង ក្នុងនោះ ដំឡើងកម្រិត ពីប៉ុស្តិ៍សុខភាពទៅមណ្ឌលសុខភាពមានចំនួន ១ កន្លែង ដំឡើងពីមណ្ឌល ទៅមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ១ កន្លែង ដំឡើងមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១ កន្លែង ដំឡើងមន្ទីរពេទ្យបង្អែកកម្រិត២ ទៅមន្ទីរពេទ្យបង្អែកកម្រិត៣ ចំនួន ១ កន្លែង ( តារាង១៥ )និងតម្រូវការបុគ្គលិកបន្ថែមចំនួន ៩១នាក់។

**តារាង១៥៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តកោះកុង ពីឆ្នាំ២០២៦-២០៣០**

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | - | - | 1 | +4 | - | - | - | - | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | - | - | - | - | - | - | - | - | - | - |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | - | - | - | - | 1 | +4 | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | 1 | +6 | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | 1 | +77 | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋានៈ**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកោះកុង មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាល សរុបចំនួន ៣កន្លែង ក្នុងនោះ ដំឡើងពីប៉ុស្តិ៍សុខភាពទៅមណ្ឌលសុខភាពមានចំនួន ១កន្លែង ដំឡើងពី មន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១ កន្លែង និងដំឡើងមន្ទីរពេទ្យបង្អែកកម្រិត២ ទៅមន្ទីរពេទ្យបង្អែកកម្រិត៣ ចំនួន ១កន្លែង (ឧបសម្ព័ន្ធ ១)។

ការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ១៣ អគារ និងសាងសង់ថ្មី/ពង្រីកចំនួន ១១ អគារ ដោយគ្រោងប្រើប្រាស់ថវិកាជាតិ និងថវិកាអង្គភាព (ឧបសម្ព័ន្ធ ២ )។

## ១០ ខេត្តក្រចេះ

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តក្រចេះ មានក្រុងចំនួន ១ ស្រុកចំនួន ៦ ឃុំ/សង្កាត់ចំនួន ៤៨ ភូមិចំនួន ៣២៧ និងប្រជាជនចំនួន ៤២៣ ៥៦៤ នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ៤ និង មានមន្ទីរពេទ្យបង្អែកចំនួន ៥ មណ្ឌលសុខភាពចំនួន ៤១ និងប៉ុស្តិ៍សុខភាព ១៣។ ផ្អែកតាមការព្យាករណ៍ របស់ក្រសួងផែនការ កំណើនប្រជាជននៅឆ្នាំ២០៣០ មានចំនួន ៤៥១ ៤៤៩នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ៩ ៨១៤ នាក់ ខេត្តក្រចេះ មានមណ្ឌលសុខភាពដែលត្រូវបង្កើតថ្មីចំនួន ៣ កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តក្រចេះ ការបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៧ កន្លែង ក្នុងនោះ មណ្ឌលសុខភាពថ្មី ៣ កន្លែង ដំឡើងកម្រិត ពីប៉ុស្តិ៍សុខភាពទៅមណ្ឌលសុខភាពមានចំនួន ៤ កន្លែង(តារាង១៦) និងតម្រូវការបុគ្គលិកបន្ថែមចំនួន ៤៥នាក់ ។

### តារាង ១៦៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តក្រចេះ ពីឆ្នាំ២០២៦-២០៣០

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 1 | +8 | 2 | +14 | - | - | - | - | - | - |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្ដិ៍សុខភាព | 1 | +6 | 1 | +6 | 1 | +6 | 1 | +5 | - | - |
| ប៉ុស្ដិ៍សុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋាន៖**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តក្រចេះ មានលទ្ធភាពបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៣ កន្លែង ក្នុងនោះមាន មណ្ឌលសុខភាពថ្មី ២កន្លែង និងដំឡើងកម្រិត ពីប៉ុស្ដិ៍សុខភាពទៅមណ្ឌលសុខភាពមានចំនួន ១កន្លែង (ឧបសម្ព័ន្ធ ១)។

ការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ១៧អគារ និងសាងសង់ពង្រីកចំនួន ៣០អគារ ដែលគ្រោងប្រើប្រាស់ថវិកាជាតិប្រមាណ ១៩ ៧១៩ លានរៀល (ឧបសម្ព័ន្ធ ២)។

## ១១ ខេត្តមណ្ឌលគិរី

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តមណ្ឌលគិរី មានក្រុងចំនួន ១ ស្រុកចំនួន ៤ ឃុំ/សង្កាត់ចំនួន ២១ ភូមិចំនួន ៩២ និងប្រជាជនចំនួន ១០៤ ២២៣ នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ១ និងមានមន្ទីរពេទ្យបង្អែកចំនួន ៣ មណ្ឌលសុខភាពចំនួន ១៦ និងប៉ុស្ដិ៍សុខភាព ១១។

ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការ កំណើនប្រជាជននៅឆ្នាំ២០៣០ មានចំនួន ១១១ ០៨៤នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ៦ ៩៤២នាក់ ខេត្តមណ្ឌលគិរី មានមណ្ឌលសុខភាពដែលត្រូវបង្កើតថ្មី ចំនួន ២ កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តមណ្ឌលគិរី គ្រោងបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ១២ កន្លែង ក្នុងនោះ ប៉ុស្តិ៍សុខភាពថ្មី ៣កន្លែង ដំឡើងកម្រិត ពីប៉ុស្តិ៍សុខភាពទៅមណ្ឌលសុខភាពមានចំនួន ៥ កន្លែង ដំឡើងពីមណ្ឌលសុខភាព ទៅមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ៣ កន្លែង ដំឡើងមន្ទីរពេទ្យបង្អែកកម្រិត២ ទៅមន្ទីរពេទ្យបង្អែកកម្រិត៣ ចំនួន ១ កន្លែង (តារាង១៧) និងតម្រូវការបុគ្គលិកបន្ថែមចំនួន ២១០នាក់។

**តារាង ១៧៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តមណ្ឌលគិរី ពីឆ្នាំ២០២៦-២០៣០**

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | - | - | 2 | +13 | 1 | +6 | 1 | +6 | 1 | +6 |
| ប៉ុស្តិ៍សុខភាពថ្មី | - | - | - | - | 1 | +2 | 1 | +2 | 1 | +2 |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | - | - | 1 | +28 | 1 | +23 | 1 | +23 |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | 1 | +99 | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋានៈ**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តមណ្ឌលគិរី មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៣ កន្លែង ក្នុងនោះ ដំឡើងកម្រិត ពីប៉ុស្តិ៍សុខភាពទៅមណ្ឌលសុខភាពមានចំនួន ២ កន្លែង និងដំឡើងមន្ទីរពេទ្យបង្អែកកម្រិត២ ទៅមន្ទីរពេទ្យបង្អែកកម្រិត៣ ចំនួន ១កន្លែង (ឧបសម្ព័ន្ធ ១)។

រីឯការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ១៨ អគារ និងសាងសង់ថ្មី/ពង្រីកចំនួន ១៦ អគារ ដែលគ្រោងប្រើប្រាស់ថវិកាជាតិ ៥ ៩៥០ លានរៀល (ឧបសម្ព័ន ២)។

## ១២ រាជធានីភ្នំពេញ

ក្នុងឆ្នាំ២០២៥ រដ្ឋបាលរាជធានីភ្នំពេញ មានខណ្ឌ ១៤ ឃុំ/សង្កាត់ចំនួន ១០៥ ភូមិចំនួន ៩៥៣ និងប្រជាជនចំនួន ២ ៥៧៩ ១៥៧នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ៧ និងមានមន្ទីរពេទ្យបង្អែកចំនួន ៩ មណ្ឌលសុខភាពចំនួន ៤៦ និងប៉ុស្តិ៍សុខភាព៥។

ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការ កំណើនប្រជាជននៅឆ្នាំ២០៣០ ចំនួន ២ ៧៤៨ ៩៥៣នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ៥៩ ៧៦០នាក់ រាជធានីភ្នំពេញ អាចពិនិត្យលទ្ធភាពដំឡើងប៉ុស្តិ៍សុខភាពបច្ចុប្បន្នទៅជាមណ្ឌលសុខភាព (**មិនមានតម្រូវការបង្កើតមណ្ឌលសុខភាពថ្មីទេ ដោយសារជាតំបន់ប្រជុំជន ប្រជុំដោយមូលដ្ឋានសុខាភិបាលគ្រប់ប្រភេទទាំងមន្ទីរពេទ្យថ្នាក់ជាតិ ឯកជនទំនើបៗ និងផ្លូវគមនាគមន៍មានភាពល្អប្រសើរមានភាពងាយស្រួលក្នុងការមកទទួលសេវា**)។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ គ្រោងបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ១កន្លែង ក្នុងនោះ គឺដំឡើងមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១ កន្លែង (តារាង១៨) និងតម្រូវការបុគ្គលិកបន្ថែមចំនួន ២១នាក់។

**តារាង១៨៖គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលរាជធានីភ្នំពេញ ពីឆ្នាំ២០២៦-២០៣០**

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | - | - | - | - | - | - | - | - | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | 1 | +21 | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋានៈ**

មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ មានលទ្ធភាពដំឡើងកម្រិតមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១កន្លែង (ឧបសម្ព័ន្ធ ១)។

ការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ១៤អគារ និងសាងសង់ថ្មី/ពង្រីកចំនួន ១អគារ ដោយប្រើប្រាស់ថវិកាជាតិ ៨២ ៣៦៨ លានរៀល (ឧបសម្ព័ន្ធ ២)។

## ១៣ ខេត្តព្រះវិហារ

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តព្រះវិហារ មានក្រុងចំនួន ១ ស្រុកចំនួន ៧ ឃុំ/សង្កាត់ចំនួន ៥១ ភូមិចំនួន ២៣២ និងប្រជាជនចំនួន ២៨៨ ០១៦ នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ១ និងមានមន្ទីរពេទ្យបង្អែកចំនួន ២ មណ្ឌលសុខភាពចំនួន ៣០ និងប៉ុស្តិ៍សុខភាព ១៥។ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការ កំណើនប្រជាជននៅឆ្នាំ២០៣០ មានចំនួន ៣០៦ ៩៧៧នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ៩ ៥៩៣ នាក់ ខេត្តព្រះវិហារ មានមណ្ឌលសុខភាពដែលត្រូវបង្កើតថ្មីចំនួន ២ កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត ព្រះវិហារ ការបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ១១កន្លែង ក្នុងនោះ ប៉ុស្តិ៍សុខភាពថ្មី ១កន្លែង មណ្ឌលសុខភាពថ្មី ២ កន្លែង ដំឡើងកម្រិត ពីប៉ុស្តិ៍សុខភាពទៅមណ្ឌលសុខភាពមានចំនួន ៣ កន្លែង ដំឡើងពីមណ្ឌលសុខភាព ទៅមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ៣ កន្លែង ដំឡើងមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១ កន្លែង ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ១កន្លែង (តារាង១៩)និងតម្រូវការបុគ្គលិកបន្ថែមចំនួន ១៩៦នាក់។

**តារាង១៩៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តព្រះវិហារ ពីឆ្នាំ២០២៦-២០៣០**

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 1 | +7 | - | - | 1 | +8 | - | - | - | - |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | 2 | +10 | - | - | - | - | 1 | +6 | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | 1 | +3 | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | 1 | +34 | - | - | 1 | +34 | - | - | 1 | +34 |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | 1 | +40 | - | - | | |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | 1 | +20 | - | - |

**ការសន្និដ្ឋាន៖**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តព្រះវិហារ មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៦ កន្លែង ក្នុងនោះ មណ្ឌលសុខភាពថ្មី ២ កន្លែង ដំឡើងពីប៉ុស្តិ៍សុខភាព ទៅមណ្ឌលសុខភាព ១កន្លែង ដំឡើងពីមណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ១ កន្លែង ដំឡើងមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១ កន្លែង និងបង្កើតការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំនួន ១កន្លែង (ឧបសម្ព័ន្ធ ១)។

ការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ៨អគារ និងសាងសង់ថ្មី/ពង្រីកចំនួន ១៣អគារ ដែលគ្រោងប្រើប្រាស់ថវិកាជាតិ ២ ២០០ លានរៀល ថវិកាដៃគូអភិវឌ្ឍ និងអង្គភាពផ្ទាល់( ឧបសម្ព័ន្ធ ២ )។

## ១៤ ខេត្តព្រៃវែង

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តព្រៃវែង មានក្រុងចំនួន ១ ស្រុកចំនួន ១២ ឃុំ/សង្កាត់ចំនួន ១១៦ ភូមិចំនួន ១ ១៦៨ និងប្រជាជនចំនួន ១ ១៩៥ ៤៧៩ នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ១២ និងមានមន្ទីរពេទ្យបង្អែកចំនួន ១២ មណ្ឌលសុខភាពចំនួន ១១១ និងប៉ុស្តិ៍សុខភាព ៦។ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការ កំណើនប្រជាជននៅឆ្នាំ២០៣០ មានចំនួន ១ ២៧៤ ១៨៣នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ១០ ៩៨៤នាក់ ខេត្តព្រៃវែង មានមណ្ឌលសុខភាពដែលត្រូវបង្កើតថ្មី ចំនួន ៥ កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តព្រៃវែង គ្រោងបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ១៥កន្លែង ក្នុងនោះ មណ្ឌលសុខភាពថ្មី ៥ កន្លែង មន្ទីរពេទ្យបង្អែកកម្រិត១ថ្មី ១កន្លែង ដំឡើងកម្រិត ពីប៉ុស្តិ៍សុខភាពទៅមណ្ឌលសុខភាពមានចំនួន ១កន្លែង ដំឡើងពីមណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ៣ កន្លែង ដំឡើងមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ៥ កន្លែង ( តារាង២០ ) និងតម្រូវការបុគ្គលិកបន្ថែមចំនួន ២៦៥នាក់។

**តារាង២០៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តព្រៃវែង ពីឆ្នាំ២០២៦-២០៣០**

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 1 | +8 | 1 | +8 | 1 | +8 | 1 | +8 | 1 | +8 |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | 1 | 6 | - | - | - | - | - | - | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | 1 | +60 | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ ( ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១ ) | 1 | +33 | 1 | +33 | 1 | +33 | 1 | +33 | 1 | +33 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋាន៖**

មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តព្រៃវែង មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៧ កន្លែង ក្នុងនោះ មណ្ឌលសុខភាពថ្មី ៤ កន្លែង ដំឡើងពីប៉ុស្តិ៍សុខភាព ទៅមណ្ឌលសុខភាព ១កន្លែង ដំឡើងមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ២ កន្លែង (ឧបសម្ព័ន្ធ ១)។

រីឯការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ១៤៦អគារ និងសាងសង់ថ្មី/ពង្រីកចំនួន ៦៥អគារ ដែលគ្រោងប្រើប្រាស់ថវិកាជាតិ ៣០ ៩៩៦ លានរៀល (ឧបសម្ព័ន្ធ ២)។

## ១៥ ខេត្តពោធិ៍សាត់

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តពោធិ៍សាត់ មានក្រុងចំនួន ១ ស្រុកចំនួន ៦ ឃុំ/សង្កាត់ចំនួន ៤៩ ភូមិចំនួន ៥២៦ និងប្រជាជនចំនួន ៤៧៤ ៦៤៧ នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ៤ និងមានមន្ទីរពេទ្យបង្អែកចំនួន ៥ មណ្ឌលសុខភាពចំនួន ៤៧ និងប៉ុស្តិ៍សុខភាព ១១ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការកំណើនប្រជាជននៅឆ្នាំ២០៣០ មានចំនួន ៥០៥ ៨៩៥ នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ៩ ៧២៩ នាក់ ខេត្តពោធិ៍សាត់ មានមណ្ឌលសុខភាពដែលត្រូវបង្កើតថ្មីចំនួន ៥ កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តពោធិ៍សាត់ ការបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៩ កន្លែង ក្នុងនោះ មណ្ឌលសុខភាពថ្មី ៥កន្លែង ប៉ុស្តិ៍សុខភាព ១កន្លែង មន្ទីរពេទ្យបង្អែកកម្រិត១ ១កន្លែង និងដំឡើងមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១ កន្លែង (តារាង២១) និងតម្រូវការបុគ្គលិកបន្ថែមចំនួន ១៥៣នាក់។

### តារាង២១៖គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តពោធិ៍សាត់ ពីឆ្នាំ២០២៦-២០៣០

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | - | - | 2 | +16 | 1 | +8 | 1 | +8 | 1 | +8 |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្ដិ៍សុខភាព | - | - | - | - | - | - | - | - | - | - |
| ប៉ុស្ដិ៍សុខភាពថ្មី | - | - | 1 | +3 | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | | | | | 1 | +110 | | | | |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | 1 | +12 | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋាន៖**

មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តពោធិ៍សាត់ មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៦ កន្លែង ក្នុងនោះ មណ្ឌលសុខភាពថ្មី ៥ កន្លែង និងដំឡើងមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១ កន្លែង (ឧបសម្ព័ន្ធ ១)។

ការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ១៧អគារ និងសាងសង់ថ្មី/ពង្រីកចំនួន ១៧អគារ ដែលគ្រោងប្រើប្រាស់ថវិកាជាតិ និងអង្គការដៃគូ(ADB) និងបុគ្គលិកបន្ថែមចំនួន ១៥៣នាក់ (ឧបសម្ព័ន្ធ ២)។

## ១៦ ខេត្តរតនគិរី

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តរតនគិរី មានក្រុងចំនួន ១ ស្រុកចំនួន ៨ ឃុំ/សង្កាត់ចំនួន ៥០ ភូមិចំនួន ២៤៣ និងប្រជាជនចំនួន ២៤៥ ៧៧៤នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ២ និងមានមន្ទីរពេទ្យបង្អែកចំនួន ៣ មណ្ឌលសុខភាពចំនួន ២៩ និងប៉ុស្តិ៍សុខភាព ៦កន្លែង។ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការ កំណើនប្រជាជននៅឆ្នាំ២០៣០ មានចំនួន ២៦១ ៩៥៥នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ៩ ០៣២នាក់ ខេត្តរតនគិរី មានមណ្ឌលសុខភាពដែលត្រូវបង្កើតថ្មី ចំនួន ២ កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តរតនគិរី គ្រោងបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៨កន្លែង ក្នុងនោះដំឡើងកម្រិត ពីប៉ុស្តិ៍សុខភាព ទៅមណ្ឌលសុខភាព ៦កន្លែង ដំឡើងកម្រិត ពីមណ្ឌលសុខភាព ទៅមន្ទីរពេទ្យបង្អែកកម្រិត១ ១កន្លែង និងដំឡើងកម្រិត ពីមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ១កន្លែង (តារាង២២)និងតម្រូវការបុគ្គលិកបន្ថែមចំនួន ១៦៣នាក់។

**តារាង២២៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តរតនគិរី ពីឆ្នាំ២០២៦-២០៣០**

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | 3 | +30 | 3 | +30 | - | - | - | - | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | - | - | 1 | +39 | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | 1 | +64 | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋានៈ**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តរតនគីរី មានលទ្ធភាពដំឡើងពីប៉ុស្តិ៍សុខភាពទៅមណ្ឌលសុខភាពចំនួន ៣ កន្លែង (ឧបសម្ព័ន្ធ ១)។

រីឯការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ២៣អគារ និងសាងសង់ថ្មី/ពង្រីកចំនួន២២អគារ ដែលគ្រោងប្រើប្រាស់ថវិកាជាតិ ៥ ៩៥០ ០០០ ០០០ និងអង្គការដៃគូរអភិវឌ្ឍ (ឧបសម្ព័ន្ធ ២)។

## ១៧ ខេត្តសៀមរាប

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តសៀមរាប មានក្រុងចំនួន ២ ស្រុកចំនួន ១១ ឃុំ/សង្កាត់ចំនួន ១០០ ភូមិចំនួន ៩០៩ និងប្រជាជនចំនួន ១ ១៤៦ ៣៣០ នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ៤ និងមានមន្ទីរពេទ្យបង្អែកចំនួន ៦ មណ្ឌលសុខភាពចំនួន ៩៣ និងប៉ុស្តិ៍សុខភាព ១១។ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការ កំណើនប្រជាជននៅឆ្នាំ២០៣០ មានចំនួន ១ ២២១ ៧៩៨ នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ១២ ៤៦៧នាក់ ខេត្តសៀមរាប មានមណ្ឌលសុខភាពដែលត្រូវបង្កើតថ្មី ចំនួន ៥ កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តសៀមរាប គ្រោងបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៦កន្លែង ក្នុងនោះមណ្ឌលសុខភាពថ្មី ៤កន្លែង ដំឡើងកម្រិត ពីមណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ២កន្លែង (តារាង២៣)និងតម្រូវការបុគ្គលិកបន្ថែមចំនួន ៩៧នាក់។

**តារាង ២៣៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តសៀមរាប ពីឆ្នាំ២០២៦-២០៣០**

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 2 | +16 | 1 | +8 | - | - | 1 | +8 | - | - |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | - | - | - | - | - | - | - | - | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | - | - | - | - | - | - | - | - |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | 1 | +33 | - | - | 1 | +32 |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋានៈ**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តសៀមរាប មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៦ កន្លែង ក្នុងនោះ បង្កើតមណ្ឌលសុខភាពថ្មី ៤ កន្លែង បង្កើតមន្ទីរពេទ្យបង្អែកកម្រិត១ថ្មី ចំនួន ១កន្លែង ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១កន្លែង (ឧបសម្ព័ន្ធ ១)។

រីឯការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ៦អគារ និងសាងសង់ថ្មី/ពង្រីកចំនួន ៥អគារ ដែលគ្រោងប្រើប្រាស់ថវិកាជាតិ( ឧបសម្ព័ន្ធ ២)។

## ១៨ ខេត្តព្រះសីហនុ

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តព្រះសីហនុ មានក្រុងចំនួន ៣ ស្រុកចំនួន ៣ ឃុំ/សង្កាត់ចំនួន ២៩ ភូមិចំនួន ១១១ និងប្រជាជនចំនួន ៣៥០ ៤៥៦ នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ១ និងមានមន្ទីរពេទ្យបង្អែកចំនួន ១ មណ្ឌលសុខភាពចំនួន ១៨ និងប៉ុស្តិ៍សុខភាព ៣។ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការ កំណើនប្រជាជននៅឆ្នាំ២០៣០ មានចំនួន ៣៧៤ ៥២៩នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ១៧ ៨៣៤ នាក់ ខេត្តព្រះសីហនុ មានមណ្ឌលសុខភាពដែលត្រូវបង្កើតថ្មី ចំនួន ៣កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តព្រះសីហនុ ការបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៦កន្លែង ក្នុងនោះមណ្ឌលសុខភាពថ្មី ៤កន្លែង ដំឡើងកម្រិត ពីមណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែកកម្រិត១ ២កន្លែង (តារាង២៤) និងតម្រូវការបុគ្គលិកបន្ថែមចំនួន១២២នាក់។

### តារាង២៤៖គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តព្រះសីហនុ ពីឆ្នាំ២០២៦-២០៣០

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 1 | +8 | 1 | +8 | | | 2 | +16 | - | - |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | - | - | - | - | - | - | - | - | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | 1 | +25 | - | - | - | - | 1 | +65 | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋាន៖**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តព្រះសីហនុ មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៥ កន្លែង ក្នុងនោះ បង្កើតមណ្ឌលសុខភាពថ្មី ៣ កន្លែង និងដំឡើងកម្រិតមណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ២កន្លែង (ឧបសម្ព័ន្ធ ១)។

ការសាងសង់ថ្មី/ពង្រីកចំនួន ៨ អគារ ដែលគ្រោងថវិកាជាតិ ៧ ១៩៦ លានរៀល (ឧបសម្ព័ន ២)។

## ១៩ ខេត្តស្ទឹងត្រែង

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តស្ទឹងត្រែង មានក្រុងចំនួន ១ ស្រុកចំនួន ៥ ឃុំ/សង្កាត់ចំនួន ៣៤ ភូមិចំនួន ១៣៧ និងប្រជាជនចំនួន ១៨៧ ២៩៦ នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ១ និងមានមន្ទីរពេទ្យបង្អែកចំនួន ១ មណ្ឌលសុខភាពចំនួន ២២ និងប៉ុស្តិ៍សុខភាព ៦។ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការ កំណើនប្រជាជននៅឆ្នាំ២០៣០ មានចំនួន ១៩៩ ៦២៦នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ៨ ៣១៧នាក់ ខេត្តស្ទឹងត្រែង មានមណ្ឌលសុខភាពដែលត្រូវបង្កើតថ្មីចំនួន ២ កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តស្ទឹងត្រែង គ្រោងបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន២៧កន្លែង ក្នុងនោះមណ្ឌលសុខភាពថ្មី ១២កន្លែង ប៉ុស្តិ៍សុខភាពថ្មី ៧កន្លែង មន្ទីរពេទ្យបង្អែកកម្រិត១ថ្មី ១កន្លែង ដំឡើងកម្រិតប៉ុស្តិ៍សុខភាពទៅមណ្ឌលសុខភាព ៦កន្លែង មណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែកកម្រិត១ ១កន្លែង (តារាង២៥) និងតម្រូវការបុគ្គលិកបន្ថែមចំនួន២៥២នាក់។

**តារាង ២៥៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តស្ទឹងត្រែង ពីឆ្នាំ២០២៦-២០៣០**

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 3 | +24 | 3 | +24 | 2 | +16 | 2 | +16 | 2 | +16 |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | 2 | +10 | 4 | +30 | - | - | - | - | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | 3 | +12 | 2 | +8 | 2 | +16 | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | 1 | +50 | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | 1 | +30 | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋានៈ**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តស្ទឹងត្រែង មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៩ កន្លែង ក្នុងនោះ បង្កើតមណ្ឌលសុខភាពថ្មី ៣ កន្លែង ប៉ុស្តិ៍សុខភាពថ្មី ៣កន្លែង ដំឡើងកម្រិតពីប៉ុស្តិ៍សុខភាពទៅមណ្ឌលសុខភាពចំនួន ២ កន្លែង និងដំឡើងមណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ១កន្លែង(ឧបសម្ព័ន្ធ ១)។

រីឯការសាងសង់ថ្មី/ពង្រីកចំនួន២០អគារ ដែលគ្រោងប្រើប្រាស់ថវិកាជាតិ(ឧបសម្ព័ន្ធ ២)។

## ២០ ខេត្តស្វាយរៀង

ក្នុងឆ្នាំ២០២៥ រដ្ឋបាលខេត្តស្វាយរៀង មានក្រុងចំនួន ២ ស្រុកចំនួន ៦ ឃុំ/សង្កាត់ចំនួន ៨០ ភូមិចំនួន ៦៩០ និងប្រជាជនចំនួន ៥៩៣ ៩៣៩ នាក់។ ចំពោះផ្នែកសុខាភិបាល មានស្រុកប្រតិបត្តិចំនួន ៤ និងមានមន្ទីរពេទ្យបង្អែកចំនួន ៦ មណ្ឌលសុខភាពចំនួន ៤៩ និងប៉ុស្តិ៍សុខភាព ១។ ផ្អែកតាមការព្យាករណ៍របស់ក្រសួងផែនការ កំណើនប្រជាជននៅឆ្នាំ២០៣០ មានចំនួន ៦៣៣ ០៤០នាក់ និងតាមមណ្ឌលសុខភាព ១ បម្រើប្រជាជនប្រហែលបច្ចុប្បន្នចំនួន ១១ ៧២២នាក់ ខេត្តស្វាយរៀង មានមណ្ឌលសុខភាពដែលត្រូវបង្កើតថ្មី ចំនួន ៥ កន្លែង។

តាមផែនការរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តស្វាយរៀង ការបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន២២កន្លែង ក្នុងនោះមណ្ឌលសុខភាពថ្មី ១៨កន្លែង មន្ទីរពេទ្យបង្អែកកម្រិត១ថ្មី ៣កន្លែង ដំឡើងកម្រិត មន្ទីរពេទ្យបង្អែកកម្រិត១ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ១កន្លែង និងតម្រូវការបុគ្គលិកបន្ថែមចំនួន២៩៩នាក់ (តារាង ២៦)។

**តារាង ២៦៖ គម្រោងផែនការបង្កើត/ដំឡើងកម្រិតមូលដ្ឋានសុខាភិបាលខេត្តស្វាយរៀង ពីឆ្នាំ២០២៦-២០៣០**

| បរិយាយ | ២០២៦ | | ២០២៧ | | ២០២៨ | | ២០២៩ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|---|---|
| | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក | អង្គភាព | បុគ្គលិក |
| មណ្ឌលសុខភាពថ្មី | 3 | +24 | 6 | +48 | 2 | +16 | 3 | +24 | 4 | +32 |
| មណ្ឌលសុខភាពដំឡើងពីប៉ុស្តិ៍សុខភាព | - | - | - | - | - | - | - | - | - | - |
| ប៉ុស្តិ៍សុខភាពថ្មី | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត១ ថ្មី | - | - | 1 | +45 | 1 | +45 | 1 | +45 | - | - |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| មន្ទីរពេទ្យបង្អែកកម្រិត១ ដំឡើងពីមណ្ឌលសុខភាព | - | - | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត២ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១) | 1 | +20 | - | - | - | - | - | - | - | - |
| មន្ទីរពេទ្យបង្អែកកម្រិត៣ (ដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត២) | - | - | - | - | - | - | - | - | - | - |
| ស្រុកប្រតិបត្តិ | - | - | - | - | - | - | - | - | - | - |

**ការសន្និដ្ឋាន៖**

មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តស្វាយរៀង មានលទ្ធភាពបង្កើតនិងដំឡើងកម្រិតមូលដ្ឋានសុខាភិបាលសរុបចំនួន ៧ កន្លែង ក្នុងនោះបង្កើតមណ្ឌលសុខភាពថ្មី ៥ កន្លែង ប៉ុស្តិ៍សុខភាពថ្មី ១កន្លែង និងដំឡើងពីមន្ទីរពេទ្យបង្អែកកម្រិត១ ទៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ១ កន្លែង (ឧបសម្ព័ន្ធ ១)។

រីឯការជួសជុលអគារមូលដ្ឋានសុខាភិបាលចំនួន ២២អគារ សាងសង់ថ្មី/ពង្រីកចំនួន ២៣អគារ ដែលគ្រោងប្រើប្រាស់ថវិកាជាតិ ៣២ ៥២២ លានរៀល (ឧបសម្ព័ន្ធ ២) ។

## ២១ ខេត្តតាកែវ

